លោក
សុទ្ធ ប៊ុលីន

# ចាក់ធ្មេញ




ផ្សាយចេញពីបណ្ណាគារបន្ទាយស្រី

# ភាគទី១

អ្នកពោល : តាមផ្លូវតូចមួយនៃក្រុង Los Angeles ជាផ្លូវឡើងជម្រាលភ្នំម៉ូ Echo Park.... ។ នៅទីនោះច្រើនតែមានផ្ទះតូចៗ ជាជួរ ពីមុខទៅក្រោយ... ដែលសម្បូរដោយបងប្អូនខ្មែររស់នៅ ។....នៅតាមផ្លូវតូចឡើងកូនភ្នំនោះ មានឡាន BMW ពណ៌សមួយ ដែលឋិតនៅចំកណ្ដាលចំណោមឡានម៉េចស៊ីកាំងកំពិតកំពៀវ...។ ខ្មែរពីរនាក់ចំណាស់កណ្ដាលមនុស្សនៅអង្គុយក្នុងឡានជជែកគ្នាមិនព្រមចេញ... ម្នាក់ឈ្មោះសរ-បាសានអាយុប្រមាណ ៤៣ឆ្នាំ ម្នាក់ទៀតឈ្មោះ មួង ឫទ្ធី អាយុ ៣៥ឆ្នាំ...។ គេនិយាយគ្នាតាមរបៀបកុនចិន ។

**ឫទ្ធី** : សិស្សច្បងឡើងទៅលើផ្ទះនោះមួយភ្លែតឬ ? អ្នកមេម៉ាយនោះស្អាតណាស់ណាំ... អាយុតែ ២២ឆ្នាំប៉ុណ្ណោះទេ...ក្ដៅស្រួយ ក្ដៅស្រួយ សាច់ឡើងកំភើៗ

**បាសាន** : ឫទ្ធិឯងឡើងទៅតែម្នាក់ឯងចុះ បងចាំនៅក្នុងឡានបានហើយ... បងដូចជាមិនសូវស្រួលខ្លួន !

**ឫទ្ធី** : សិស្សច្បង ប្រយ័ត្នស្ដាយក្រោយ... បងស្រីអាយុ

តែ ២២ទេ Perfect !! ហាំងមានកូនតែមួយប៉ុណ្ណោះ បងស្រីថ្មី ឈ្មោះវណ្ណី ហើយមុខមាត់គាត់ស្រដៀងគ្នានឹងមុខមាត់បងស្រី សោភានីរបស់បងឯងពីមុនកាលនៅ San Jose...I know she is your type បង !

**ចាសាន** : មែន អី ?

**ឬទ្ធី** : Positive !

**ចាសាន** : សិស្សប្អូនដូចជាគួរសមពេកទេដឹង ? បើនាងនោះស្អាតពិតមែន សិស្សប្អូនម្តេចមិនពិសាខ្លួនឯងទៅ ! ម្តេចចាំបាច់ធ្វើមេអណ្តើកឲ្យគេ ?

**ឬទ្ធី** : លាក់បាំងអី...នាងនោះ ខ្ញុំញ៉ូវាមិនបានៗ ជាខ្ញុំចង់ទុកឲ្យបងឯង ។ សិស្សច្បងយុទ្ធសិល្បខ្ពស់ជាងប្អូន...ម្យ៉ាងវិញទៀត ប្អូនមានទៀតទៅហើយ នរណាទៅហ៊ានកាត់មុខកាត់មាត់សិស្សច្បងនោះ ?

**ចាសាន** : ហ៊ឺ... ឬទ្ធីឯងឡើងទៅម្នាក់ឯងចុះ បងដូចជាមិនសូវចង់ទេ.... ប៉ុន្មានថ្ងៃមុននេះបងមានយល់សប្តិឃើញបាក់ធ្មេញ ព្រមទាំងចេញឈាមផង... កាលណាបងយល់សប្តិឃើញបាក់ធ្មេញ...ដូចជាមិនសូវស្រួលទេប្អូនអើយ. បងចេះតែបារម្ភ...

**ឬទ្ធី** : សិស្សច្បង ! មកដល់កន្លែងដើមឈើក្រអូបហើយ



មិនគិតរត់ទៅរកទេ ! Please! ឈប់គិតបន្តិចសិនមើល... you think too much... មិនដឹងជា Philo មិនដឹងជា Meditate ស្អីងស្មាធីច្រើនអ្វីម្ល៉េះទេ... រឿងបាក់ធ្មេញទៀតក៏មិនចេះអស់ ....ចុះក្រែងបងឯងប្រាប់ខ្ញុំថា រឿងបាក់ធ្មេញនោះ ជាធ្មេញបាក់មែនទែន រហូតដល់ធ្វើឲ្យប្រពន្ធបងរត់ចោលរួចទៅហើយ... ជារឿងចាស់គីរីលយូរយារណាស់មកហើយ រួចឥឡូវក៏មកមានរឿងយល់សប្តិបាក់ធ្មេញអ្វីទៀតហើយ ! ។ ខ្លាមិនខ្លាច បែរជាខ្លាចអាចម៍ខ្លា...គួរដែរ ! គួរដែរ ! បងប្រុសខ្ញុំមិនដែលជឿអារក្សទេព្រ័ក្ស អ្នកតា ទេព្តា ខ្មោចបិសាចអ្វីទាំងអស់...ស្រាប់តែឥឡូវបែរជាមកខ្លាចយល់សប្តិទៅវិញ គួរឲ្យអស់សំណើច ! ហេ ! ហេ !

**ចាសាន** : ឬទ្ធី ប្អូនប្រុស ! រឿងខ្លះយើងគួរជឿខ្លះដែរ... អាគមផ្សំអាយ៉ូស !...កាលបងបាក់ធ្មេញមួយ...គឺធ្មេញចំហៀងនៅក្បែរថ្គាមខាងឆ្វេង កាលណោះបណ្តាលឲ្យសោភានីរត់ចោលបង ព្រោះវាភ័យខ្លាចបងស្លាប់ចោលវា... រឿងនោះ គឺរឿងបងសង្កេតចិត្តស្រី ពឹងផ្អែកលើការពិសោធ ពុំមែនជារឿងគួរជឿឬរឿងមិនគួរជឿនោះទេ...។ ប៉ុន្តែរឿងយល់សប្តិជារឿងផ្សេង... កាលណាបងយល់សប្តិឃើញថាបាក់ធ្មេញ គឺតែងតែមានញាតិមិត្តស្លាប់ពិតប្រាកដ ជាពិសេសគឺប៉ះពាល់ដល់សាច់ឈាមជិតៗទៀតផង !

**ឫទ្ធី** : ខ្ញុំយល់សប្តិឃើញបាក់ធ្មេញតែញយហ្នឹងឯង...ប៉ុន្តែមិនដែលមានកើតហេតុម្តងណាសោះ...ហើយបើកាលណាខ្ញុំយល់សប្តិឃើញបាក់ធ្មេញហូរឈាមមួយកំភ្លួសថែមទៀត គឺច្បាស់ជាមានលាភជាមិនខាន... គឺខ្ញុំអាចទៅលេងល្បែង Black Jack នៅ Las Vegas ទៀតផងណាសិស្សច្បង ។

**ចាសាន** : បងនិយាយប្រាប់ប្អូនអញ្ចឹងពីព្រោះបងធ្លាប់មានរឿងហេតុម្តងរួចហើយ ។ កាលពីឆ្នាំមុនបងមានសង្សារជានិស្សិតស្រីសៀមម្នាក់... នាងនោះជានារីក្រមុំព្រហ្មចារី អត់ព្រមប្រគល់ខ្លួនឲ្យនរណាទេ ប៉ុន្តែថ្ងៃកើត Earth quake ខ្លាំងជាងគេនៅ Northbridge នោះ បងបានទៅលេងផ្ទះនាងដោយចៃដន្យ ។ ដោយនាងខ្លាចស្លាប់ទៅនៅភាពជាក្រមុំ នាងក៏បានប្រគល់ព្រហ្មចារីមកឲ្យបង... យើងក៏បានក្លាយជាសង្សារនឹងគ្នានៅចំពេលដែលផែនដីញ័រខ្លាំងតែម្តង ! ហើយ ប្ញទ្ធីដឹងយ៉ាងម៉េចទេ ? ប៉ុន្មានថ្ងៃក្រោយមកស្រាប់តែបងយល់សប្តិឃើញបាក់ធ្មេញ... បងចេះតែពិភាល់... ចេះតែមមៃគិតព្រួយបារម្ភថាមានបងប្អូនណាម្នាក់មានគ្រោះថ្នាក់ជាមិនខានហើយ... ម្នាស់ថ្លៃ គឺប៉ះចំនាងសង្សារសៀមនោះតែម្តង ! ពេលភ្លើងឆេះព្រៃ នៅខាងជើង អិល-អេ... នាងបើកឡានតាមចង្កេះភ្នំចំកន្លែងមួយដែល



គេជួយមិនទាន់ នាងក៏ត្រូវឆេះខ្លោចដូចសត្វកណ្តុរអ៊ីចឹង... នេះគឺជារឿងបង ! ប្អូនឃើញទេ ? សង្សារមែនទែនក៏បង់...សង្សារចម្លងភក់ក៏បាត់ !!! Shit !....

**ឫទ្ធី** : ចុះក្រែងនាងសៀមនោះបានស្លាប់ទៅដូចគោលបំណងហើយទេតើ... ដូចដែលនាងបានព្រាងទុក គឺបានសិស្សច្បងស្រោចគល់...ប្រោះព្រំទឹកអម្រឹតរួចជាស្រេច...ហា ! ហា ! ហា ! កុំអីនាងស្លាប់ទៅវិញ Free ឥតទាំងបានស្គាល់ជាតិព្រះមេផង ហា ! ហា !

**ចាសាន** : បងមិនមែនចង់និយាយអ៊ីចឹងទេ បងចង់និយាយថា យល់សប្តិបងវា "ឆុត"

**ឫទ្ធី** ចុះក្រែងយល់សប្តិនោះវាកើតមានតាំងពីកាលឆ្នាំមុនម្ល៉េះ... វាមិនទាក់ទងអីដែរជាមួយនឹងអានី Honey ឆ្នាំអូនដប់ប្រាំមួយស្រួយខ្ញោក ហែកខ្ញោកដាច់សាច់ក្រក... ដូចនំប៉ុងថ្មីៗ... ម៉េម៉ាយ អិល-អេ ឯណេះ ?

**ចាសាន** : ចុះប្អូនឯងថានាងនោះអាយុ ២២ទៅហើយ... ឥឡូវម្តេចក៏បែរជាអាយុ ១៦ទៅវិញ ?

**ឫទ្ធី** : ២២មែន... ប៉ុន្តែមើលមុខឃើញនៅខ្ចីល្អក់ដូចមនុស្សទើបចូលវ័យជំទង់...។ (ឫទ្ធីច្រៀង) ឆ្នាំអូនដប់ប្រាំមួយ... វ៉ាចត្រលោម ! វ៉ាចត្រលោម !

បាសាន : ប្អូនឡើងទៅចុះ... បងគ្មានកម្លាំងចិត្តឡើងទៅជាមួយប្អូនទេ

ឫទ្ធី : ម៉េចអ៊ីចឹង សិស្សច្បង ? Why ?

បាសាន : ពីព្រោះកាលយប់មិញ បងយល់សប្តិឃើញបាក់ធ្មេញម្តងទៀតហើយ !

# ឆាកទី២

## (ដាក់ភ្លេងស្រណោះ)

ពោល : ការហក់វិលត្រឡប់នៃចំណិតតូចមួយនៃអតីត-កាល ។ ពេលដែលនាយឫទ្ធីបើកទ្វារឡានចេញទៅ... បាសានប្រែរជានឹកស្រណោះដល់សោភានីភរិយាក្មេង ដែលខ្លួននៅតែនឹកស្រឡាញ់មិនទាន់រសាយ ។ ដោយសារតែមានមនោសញ្ចេតនាជាមួយនឹងប្រពន្ធមុននេះហើយ... ទើបបានបាសានមិនសូវជាចង់ស្គាល់ស្រីណាថ្មីទៀតទាល់តែសោះ... ប៉ុន្តែបាសានខំភរភូតខ្លួនឯងថាគេលែងនឹកនា លែងស្រណោះសោភានីទៀតហើយ ។ តាមពិតសោភានីជាឧបសគ្គនៃស្នេហាថ្មីរបស់បាសាន ។ "មនុស្សយើងគឺជាសត្វដែលលង់ទ្រនេសក្នុងទីឆ្ងាយ ៗ" យោងតាមយោបល់របស់ទស្សនវិទូអាល្លឺម៉ង់ Heidegger “L’homme c’est l’être des lointrains” មនុស្សតែងរស់ជាប់ទ្រុងអតីតកាលជាមួយគ្នានឹងការភ័យខ្លាចតក់ស្លុតចំពោះអនាគតកាល... ប៉ុន្តែគេពុំបានរស់ក្នុងបច្ចុប្បន្នសោះឡើយ... ម្លោះហើយបានជាគេភ្លេចភ្លាំងរបូតខ្លួនទៅទីឆ្ងាយ ៗ ។ ដោយហេតុតែបាសានជាប់ទ្រុងអតីតកាលជាប់ជំពាក់នឹងសម្រស់សោភានីដោយមិនដឹងខ្លួននោះឯង ទើប

បានជាគេមិនព្រមឡើងតាមជម្រាលភ្នំជាមួយនឹងបូទ្ធី ទៅជួបអ្នកមេម៉ាយថ្មីស្រីសង្សារជាយថាហេតុ...។ ចំណែករឿងយល់សប្តិបាក់ធ្មេញ...និងស្រីនិស្សិតសៀមដែលស្លាប់ក្នុងអគ្គីភ័យនោះគឺប្រហែលគ្រាន់តែជាលេសប៉ុណ្ណោះទេដឹង ។ នៅពេលដែលបាសានគេនឹកថា គេលែងស្រឡាញ់សោភានីទៅហើយនោះ...គឺជាពេលដែលគេកំពុងស្រឡាញ់នាងខ្លាំងជាពន់ពេក ! បីឆ្នាំទៅហើយដែលស្រមោលរបស់នាងមិនព្រមរលត់បាត់ពីដួងព្រលឹងរបស់គេសោះ...។ បាសានហាក់ដូចជារើបម្រះពីអន្លង់ស្នេហ៍ចាស់ ដោយពោលរអ៊ូរទាំហាក់ដូចជានិយាយទៅរករថយន្តរបស់បូទ្ធី... ទៅរកអ្នកតាចាស់ស្រុក... ឬទៅរកទេព្តា អិល-អេ ? គឺជាសេចក្តីតូញត្អូរដែលជាការប្រឹងរើបម្រះដោះខ្លួនពីស្នេហាអភ័ព្វក្នុងអតីតកាល ។ (ភ្លេង...)

**បាសានៈ** ស្រឡាញ់រួចក្តាញ់ រួចភ្លេច !...រួចហើយក៏ស្រឡាញ់ទៀត !! ឱ ! វេទនាអ្វីម្ល៉េះខ្ញុំ....គេឯទៀតគេមានមនោសញ្ចេតនាស្នេហាជាតិ គេរត់ទៅបម្រើប្រយោជន៍ស្រុកទេសរហូតដល់បានធ្វើរដ្ឋមន្ត្រីនិងពាក់ផ្កាយគ្រប់ៗគ្នា... ចម្លែកអ្វីខ្ញុំបានជាមានវាសនាស្លាប់តែនៅក្រោមកន្ទុយក្បិន I am designed to be hopeless ! តាំងពីឃ្លាតចាកស្រុកកាលណា ខ្ញុំមិនដែលបាន នឹកនាទៅដល់



មាតុប្រទេសម្តងណាឡើយ... ខ្ញុំនឹកស្រណោះតែ ទៅដល់អូនសោភា... សែនស្តាយលែងបានក្លែមខ្លួនសង្សារ" បើផុតជ្រោយមួយ បងមិនស្រណោះ បើផុតចុងដោះ ស្រណោះដាច់ខ្យល់ !" ភ្លេង....

ខ្ញុំមិនសូវចូលចិត្តនឹកឃើញដល់ស្រីណា ដែលខ្ញុំធ្លាប់ស្រឡាញ់ម្តងរួចហើយនោះទេ ប៉ុន្តែរួចហើយខ្ញុំនៅតែនឹកដដែល !

**អ្នកពោល** : តើបានផលប្រយោជន៍អ្វីទៅ ? យើងធ្លាប់ក្តាញ់រួចម្តងទៅហើយ កាលណាយើងឃើញគ្នាម្តងទៀត...វានាំតែអនុញ្ញាតឲ្យដំបៅចាស់ហាក់ត្រឡប់មកវិញទាំងកម្រោលតែប៉ុណ្ណោះ...នាំតែឲ្យយើងក្តាញ់ម្តងទៀតនោះឯង ។ ការស្រឡាញ់ដែលបាត់បង់ទៅហើយ...មិនអាចវិលត្រឡប់វិញឡើយ ។ របស់អ្វីដែលកសាងរួចហើយដោយសារព្រហ្មលិខិត មិនអាចរុះរើឡើងវិញបាន ដោយសារព្រហ្មលិខិតដូចគ្នា ។ ឧបមាថា បើគេជួបប្រទះស្រីដែលគេធ្លាប់ស្រឡាញ់រួចម្តងហើយ... ស្រីនោះឯងក៏លែងជាស្រីដដែលដូចដែលគេបានស្គាល់ពីមុន ។

**បាសាន** : ខ្ញុំមិនសូវចូលចិត្តនឹកទៅរឿងស្នេហាចាស់នោះទាល់តែសោះ... ពីព្រោះកាលណាខ្ញុំអណ្តែតអណ្តូងទៅអតីតកាល អតីតកាលនោះវាក្លាយទៅជាឧបសគ្គរបស់អនាគតកាលរបស់ខ្ញុំ ។

ខ្ញុំរកប្រពន្ធថ្មីលែងបាន ។ អតីតកាលជាអាហារចាស់...ស្នេហាចាស់ រឿងចាស់ ! ។ ខ្ញុំមិនចូលចិត្តធ្វើកំហុសពីរដងទេ គឺការធ្វើខុសនោះផង....ហើយនិងការស្តាយនោះផង ។ ខុសម្តងគឺវាខុសទៅហើយ... ខុសម្តងទៀតគឺការស្តាយស្រណោះ ។ ស្តាយចុះស្តាយឡើង តាំងរករឿងខុសម្តងទៀតហើយ ! ។ ព្រោះការស្តាយកំហុសជាកំហុសទី២របស់យើង... ហើយអនុស្សាវរីយ៍នោះឯងជាកំហុសទី២ ។

អ្នកពោល : ប៉ុន្តែនៅពេលដែលយើងរកអនាគតមិនបានគឺមានតែសំណល់រឿងចាស់នោះហើយ ! ដែលជាទ្រព្យសម្បត្តិរបស់យើង !

បាសានក៏នឹកដល់បុព្វហេតុដែលបានធ្វើឲ្យប្រពន្ធទី៧របស់គេ រត់ចោលគេកាលនៅសាន់ហ្វូសេ ។ គឺនាងមេម៉ាយកូនពីរអាយុ២២ សោភានីនោះឯង ! បាសានក៏បានក្លាយខ្លួនជាមេទ័ពមេទឹង... រីឯងកូនទ័ពគឺជាកូនទាហានរបស់គេសុទ្ធសាធ ។ គឺកូនគេមានស្រាប់ៗដែលបាសានពុំបានឆ្លាក់ច្នៃប្រឌិតអ្វីទាំងអស់ មានសក់ពណ៌ទង់ដែងច្រមុះស្រួច ។ ប្តីនាងមុន...គឺមុនបាសាន...ជាអាមេរិចកាំងស្បែក-ស មានអាយុប្អូនបាសានស្ទើរមួយជួរ ។ ថ្ងៃមួយបាសានបានសួរសោភានីថា :



**បាសាន** : អានីឯងម្តេចស្រឡាញ់ប្តីចាស់ ? ហើយម្តេចបានលែងប្តីក្មេង ?

**សោភានី** ខ្លួនខ្ញុំក៏ចាស់ដែរ... មើលច្រឡំៗតែពូឯងហ្នឹង !! មើល៍...សក់ខ្ញុំមានស្កូវខ្លះៗ ទៅហើយ...

អ្នកពោល : នាងខំរែកសក់ស្វែងរកស្កូវឲ្យបាសានមើល.. ដែលពុំមានមួយសរសៃសោះ...

**សោភានី** : ម្យ៉ាងទៀត ខ្ញុំចូលចិត្តមនុស្សចាស់ ព្រោះមនុស្សចាស់មានចិត្តនឹងនរ ទៀងត្រង់ និងចេះថ្នមប្រពន្ធដូចពូឯងអ៊ីចឹង ។ ជួនកាលមនុស្សចាស់... វាដូចតែផ្លែឈើស្រគាលនោះដែរ... វាអាចឆ្ងាញ់ជាងផ្លែឈើខ្ចីផងណា... ពូសាន !

**បាសាន** : ចុះឧបមាថា បើថ្ងៃមួយបងធ្លាក់ក្រ អានីសុខចិត្តនៅជាមួយពូតទៅទៀតទេ ?

**សោភានី** : អូ ! ខ្លួនខ្ញុំបើប្តីធ្លាក់ក្រ ខ្ញុំរឹតតែក្រាញនៀលតស៊ូជាងមុនទៅទៀត... ដូចនារីគ្រប់លក្ខណ និងពិជ័យកើតឃ្លង់តែកាលណាប្តីអភ័ព្វ ខ្ញុំរឹតតែអាណិតអាសូរបេះលែងដាច់តែម្តង។ នែ៎ ! ពូសាន ម្តេចបានគិតច្រើនម្ល៉េះ ? មិនគឺពូឯងដែលនិយាយប្រាប់ខ្ញុំថា មនុស្សយើងកាលពីព្រេងនាយមានដៃបួន ជើងបួនមានឫទ្ធានុភាពសឹងប្រហែលព្រះឥសូរ... មនុស្សក៏កើតមានចិត្ត

ព្រហើនកោងកាចរហូតដល់ព្រះទ្រង់គ្រោធយកទៅកាត់ជាពីរកំណាត់...មួយកំណាត់នៅសល់តែដៃពីរ ជើងពីរ....ម៉្លោះហើយមួយកំណាត់ៗ ដែលព្រះបានកាត់នោះក៏បានក្លាយទៅជាសង្សារស្វែងរកគ្នាមិនចេះស្ងាង ។ កាលណាសង្សារស្វែងរកកំណាត់របស់ខ្លួនឃើញ...ក៏បានជួបប្រទះនឹងសុភមង្គល... ប៉ុន្តែបើច្រឡំកំណាត់មួយដែលជារបស់គេនោះ នឹងក្លាយទៅជាគូកម្ម ។ ចំណែកពូសានឯងហើយនិងខ្ញុំ យើងជាគូព្រេងនឹងគ្នាមែនទែន ថ្វីបើអាយុខុសគ្នាបន្តិចបន្តួចក៏ដោយ...យើងជាសង្សារនឹងគ្នាមែនពិត...ជាកំណាត់ដែលព្រះបានកាត់ចេញពីគ្នាជាក់ស្តែង... គឺជាកំណាត់សម្រាប់បំពេញគ្នាទៅវិញទៅមក ។ ពូឯងមើល... ពូឯងនិងខ្ញុំចិត្តក៏ត្រូវគ្នា ថ្លើមក៏ត្រូវគ្នា ខ្លួនពីរក៏ដូចខ្លួនមួយ ខ្នើយមួយពីរ-នាក់...ដាក់កន្លែងណាក៏ត្រូវគ្នា ស្មើដូចគេវាស់...

**បាសាន** : អានី... ចុះឧបមាថាបើពូត្រូវដាច់សរសៃក្បាល Stoke ងាប់ខ្លួនមួយចំហៀង...ដូចបងឈុំនោះ... តើអានីនៅថែរក្សាពូទេ មើលទៅ...?

**សោភានី** : ច្បាស់ជានៅថែរក្សារហូតអវសាន...ខ្ញុំនឹងស្រឡាញ់ពូឯងឡើងមួយជាដប់... យី ! ម្តេចបានពូឯងនិយាយអីចឹង...? តើឲ្យខ្ញុំធ្វើម្តេចទៀតទៅឲ្យឃើញថា ខ្ញុំស្រឡាញ់ពូឯងអីចឹងនោះ ?



អ្នកពោល : និយាយដូច្នេះហើយ សោភានីក៏ស្ទុះទៅឱបរឹតបាសាន ។ កាលនោះបាសាននឹកសែនត្រេកអរ អណ្តែតអណ្តូងស្រាលខ្លួនដូចសំឡី ព្រោះស្មានតែសោភានីនិយាយត្រង់ ។ បាសាននឹកស្មានថាគេស្រឡាញ់រូបខ្លួនពិតមែន បាសានកំពុងតែនឹកយ៉ាងរបៀបរំភើបថា... (ភ្លេងបន្តិច)

**បាសាន** : នែ៎អាត្មាអញចាស់មែន ស្ទើរតែមានអាយុដំណាលនឹងឪពុកអានីទៅហើយ ប៉ុន្តែវាស្រឡាញ់ឯងជាងប្តីក្មេងរបស់វាទៅទៀត...នែ៎ !! ។... ប្រហែលជាអញមានតម្រិះដ៏សមគួរ...ចេះបំពេញគោលបំណងរបស់អានីជាងប្តីមុនទេដឹង ? ប្រហែលជាអញមានអ្វីមួយសង្ហាដែរ... ជាសម្ងាត់ផងក៏មិនដឹង ? ដូចជាការធន់ទ្រាំតស៊ូក្នុងល្បែងស្នេហា... ចរិតទៀងទាត់... កម្លាំងកំហែងក្មេងៗ ល្មមមិនដល់...ទើបបានធ្វើឲ្យស្រីក្មេងខ្ចីនេះជាប់ចិត្តស្រឡាញ់រូបអញដល់ម្លេះ ?

អ្នកពោល : បាសានចេះតែនឹកសរសើរខ្លួនឯងថាបានប្រពន្ធសំណព្វ គឺមកដល់ប្រពន្ធទី៧ ។ គេចេះតែគិតថា ខ្លួនគេគ្រាន់តែជារាស្ត្រតូចតាចម្នាក់សោះ...។ ការយល់ច្រឡំនេះជាកំហុសដ៏ធ្ងន់ធ្ងរបំផុតរបស់បាសាន ។ តាមពិតសោភានីស្រឡាញ់ប្តីចាស់...ក៏ព្រោះតែនាងស្វែងរកប្តីក្មេងមិនទាន់បាន ឬក៏មិនបាន

របស័សទាន់ចិត្តតែប៉ុណ្ណោះ ។ នាងត្រូវការបាសានជាអ្នកបម្រើ ចេះលត់ចេះដំ មានលក្ខណសម្បត្តិស្លូតបូត ចេះគួរសម ហើយប្រកបដោយសុជីវធម៌ថ្លៃថ្នូរ ។ នាងត្រូវការឲ្យបាសានជួយពរកូនរបស់នាងយកទៅផ្ញើត្រង់កន្លែងគេមើលកូន ។ បាសានជាមនុស្សចាស់ ពកូនគេដែលមានសក់ពណ៌ទង់ដែង និងសក់ពោតទាំងពីរនាក់នោះមិនដឹងជាណាមួយប្រុស... មិនដឹងជាណាមួយស្រីនោះទេ... ព្រោះបាសានពុំបានពិនិត្យមើលវាដោយជិតដិតផង...ស្គាល់តែម៉ែប៉ុណ្ណោះបានច្បាស់លាស់ ។ ជួនកាលក្លិនកន្ទបកូនក្មេងជះចំហាយមកលើចង់ឈ្លក់ ។ ប៉ុន្តែបាសានខំធ្វើព្រងើយធ្វើវាហីបែបមិនដឹងខ្លួន ។ បាសានជាមនុស្សចាស់ដើរតាមក្មេងស្រីនៅកណ្តាលហ្វូងសាធារណជនដោយគ្មានការអាម៉ាស់...ចូលតាមរបងផ្ទះអ្នកស្រុក...តត្រុក... ដោយមុខក្រាស់និងមុខក្តាញ់.. គ្មានញញឹម គ្មានខ្លាចនរណាមើលងាយ ។ នាងសោភានីស្រីស្រស់ក្មេងជាអ្នកធ្វើការរត់ការឲ្យមេធាវីផង... ជាអ្នករត់ប្រាក់ពិការផង... ដែលអ្នក San Jose ប្រសិទ្ធនាមថា អ្នករកស៊ីទាក់ឆ្កែ ។ ម្ល៉ោះហើយជួនកាលនាងស្រីសោភានីត្រូវការឲ្យបាសានធ្វើជាអ្នកបើកបរឡានរបស់នាង បើកជូននាងទៅ Stockton, Modesto, Fresno, Long Beach ។ គឺគ្មានបានការអ្វីសំខាន់ទេចំពោះបាសាន... នាងត្រូវការបាសានជាអ្នកបម្រើ... និងជាអ្នកយាម



ល្បាត...ជាអង្គរក្ស ដើររក "Case" ឲ្យនាងតែប៉ុណ្ណោះឯង ។ ជួនពេលខ្លះបាសានក៏កើតមានចិត្តស្រណោះអាណិតអានាថខ្លួនថែមទៀតផង...(ភ្លេង)

**បាសាន :** គឺនាងបានត្រឹមតែបង្ខាតពេលរបស់ខ្ញុំ...។ ហើយនាងដាក់ទានថ្លៃឈ្នួលឲ្យខ្ញុំ....ជួនកាលមួយអាទិត្យបានពីរដង... ជួនកាលមួយអាទិត្យបានម្តង ។ ...គឺដូចខ្ញុំជាអ្នកសុំទានដូច្នេះឯងធ្វើការឲ្យគេឥតកម្រៃ... ធ្វើចៃរបស់គេ ធ្វើអ្នកលុតក្រាបដូចអ្នកសុំបុណ្យស្តេច... ហើយ... ហើយនឹកថាខ្លួនឯងជាបុរសដែលគេស្រឡាញ់ថែមទៀត !?

**អ្នកពោល :** បាសានបានដើរតាមនាងកក្លិកកក្លាក់រហូតដល់បាត់បង់មិត្តភ័ក្តិ...រហូតអស់ការងារដែលគេធ្លាប់ធ្វើ...ស្រាប់តែថ្ងៃមួយ... បាសានបាក់ធ្មេញ បាក់ធ្មេញមែនទែន...មិនមែនយល់សប្តិទេ.... ដោយខាំផ្លែត្របែកនៅក្នុងសណ្ឋាគារមួយនៅ San Jose ។ បាសានបានបង្ហាញធ្មេញបាក់របស់គេឲ្យនាងឃើញ...ក៏ស្រាប់តែនាងមានការតក់ស្លុត...បើកភ្នែកមូល១ដូចគេឃើញ ខ្មោចតៃហោង ។ ចំណែកបាសានដែលធ្លាប់តែនឹកស្មានច្រឡំថា សោភានីនាងស្រឡាញ់មនុស្សចាស់ដូចរូបគេ ក៏ដឹងខ្លួនភ្ញាក់ស្វាងនៅពេលនោះ បាសានដឹងខ្លួនថារូបគេពុំមែនត្រឹមតែជាមនុស្សចាស់ទេ... តែជាមនុស្សស្លាប់បាត់ទៅហើយចំពោះនាង

សោភានី។ គ្រាន់តែឃើញធ្មេញបាក់របស់បាសាន...សោភានីក៏ស្រាប់តែ មើលឃើញអនាគតរបស់នាងតែម្តង...ដែលក្លាយទៅជាអតីតកាលរបស់បាសាន ។

ល្ងាចនោះនាងមេម៉ាយកូនពីរ សោភានី ២២ដួងចិត្តរបស់បាសានក៏បានវេចសំពាយព្រមទាំងប្រមូលកូនទាំងពីររបស់នាងបើកឡានរត់ចោលបាសានធ្វើដំណើរទៅក្រុង Los Angeles តែម្នាក់ឯង...។ បាក់ធ្មេញមួយមេម៉ាយរត់ចោល កាយវិការតក្កទល់ពុទ្ធោនេះ... គឺហាក់ដូចជាសោភានីយករូបបាសានទៅបោះចោលក្នុងធុងសម្រាម ប្រហែលគ្នានឹងអាហារចាស់... ឬលើសពី

នេះទៅទៀត...គឺហាក់ដូចជាការយកបាសានទៅកប់ទាំង រស់តែម្តង ធ្វើឲ្យគេឈឺចាប់ចុកឈាមខ្លោចផ្សា ! (ភ្លេង...)

ទូរស័ព្ទនៅក្នុងរថយន្ត BMW រោទិ៍គ្រឹង ! បាសានលើកឡើងឮសំឡេង ឫទ្ធី....

ឫទ្ធី : សិស្សច្បង...សូមអញ្ជើញឡើងមកមួយភ្លែត...មានការសំខាន់ណាស់...ផ្ទះលេខ 277½...Please...don't say no...

បាសាន : Ok... ទៅក៏ទៅ....

បាសានដាក់ទូរស័ព្ទចុះ.... (ភ្លេង)

# ភាគទី៣

អ្នកពោល : ពេលបាសានដើរមកដល់មុខគេហដ្ឋានរបស់អ្នកមេម៉ាយថ្មី នៅលើចង្កេះភ្នំ Echo Park... គេឃើញសុភាពបុរស ឫទ្ធី ឈរចាំនៅមាត់ទ្វារជាស្រេចដើម្បីស្វាគមន៍ ។ គឺជាផ្ទះមួយតូចទាបជាប់នឹងដី... មានដាំដើមល្ហុងពីរដើមនៅពីខាងមុខ....ដើម្បីចូលទៅបានគេត្រូវឡើងតាមជណ្តើរមួយដែលមានកម្ពស់កន្លះម៉ែត្រប៉ុណ្ណោះដែលនៅលាក់សម្ងំខ្លួនពីក្រោយដើមល្ហុងនោះ ។

ឫទ្ធី : សិស្សច្បងអញ្ជើញមកតាមនេះ...សូមកុំទើសទាល់ឲ្យសោះ សូមចាត់ទុកជាផ្ទះសិស្សច្បងទៅចុះ... Sound (ឮសូរសំឡេងទ្វារដែលបើក... ព្រមទាំងសម្រឹបជើងរបស់អ្នកទាំងពីរចូលក្នុងផ្ទះក្រាលក្តារ... ឮសំឡេងកៅអីមួយដែលឫទ្ធីទាញដាក់ឲ្យបាសានអង្គុយ)

បាសាន : ប្អូនឯងថាមានការសំខាន់ណាស់ តើជាការអ្វីទៅ ?

ឫទ្ធី : ខ្ញុំចង់ឲ្យសិស្សច្បងមកកំដរខ្ញុំផងតែប៉ុណ្ណោះ !... ឆ្នូឡាវហឿង មិនត្រូវបោះបង់ចោល ហ្វូទាហ្វ ឲ្យនៅកម្សត់ម្នាក់ឯងនោះទេ

**បាសាន** : ចុះម្ចាស់ផ្ទះគេទៅណាហើយ ?

**ឫទ្ធី** : គេនៅក្នុងបន្ទប់ទឹក គេចេញមកឥឡូវហើយ... បងឯងចាំមើលតែឃើញគេ បងឯងច្បាស់ជាលោតជើងបី ជើងបួនជាមិនខាន... គឺជាសម្រស់លាក់ខ្លួន គន់យូរកាន់តែប្រិមប្រិយ

**បាសាន** : ចុះប្អូនឯងមកជួបគេមានការអ្វីដែរ ?

**ឫទ្ធី** : ខ្ញុំបានធ្វើ Appointment ជាមួយនាង... ព្រោះនាងបានសុំឲ្យខ្ញុំជួយរកការងារមួយឲ្យនាងធ្វើ... ដោយស្រុកឥឡូវវាតឹង នាងចង់រត់ឲ្យរួចពីប្រាក់ Welfare.... ប៉ុន្តែមើលទៅដូចជាពិបាកបន្តិចហើយបងអើយ... នាងធ្លាប់រៀនចប់ High School ទៅហើយ ប៉ុន្តែមិនធ្លាប់ធ្វើការនៅ Office អ្វីទេ ធ្លាប់តែដេរនៅផ្ទះ ។ ប៉ុន្តែតាមមើលទៅ នាងប្រហែលជាចង់រកប្តីខ្មែរតែប៉ុណ្ណោះទេក៏មិនដឹង....ពីព្រោះអាសង្សារប៉ាគីស្ថានរបស់នាងវាត្រឡប់ទៅលេងស្រុកវាវិញ ប្រហែលជិតមួយខែទៅហើយ... អត់ទាន់ឃើញវាត្រឡប់មកវិញ ! !

អ្នកពោល : ឮដូច្នេះ នាយបាសានបើកភ្នែកឡើងគ្រលួងមូលប៉ុនគ្រាប់ឃ្លី !

**បាសាន** : ចូញម្រ៉ូញ !! បើនាងមានសង្សាររួចទៅហើយ ម្ដេចក៏ចាំនាំបងមកជួបនាងធ្វើអ្វី ?...ឫទ្ធី ប្អូនប្រុស...បងមិនចេះ



លួចសង្សារគេទេ !... អារឿងក្ដៅក្រហាយមួយ បងមិនចង់បានទេ... បងចង់បានតែអារឿងត្រជាក់ត្រជំ ត្រីកុំសុខដុមរមនា... សូវឲ្យគេលួចសង្សាររបស់បងទៅចុះ មិនថ្វីទេ It's OK... ចំណែកអារឿងលួចរបស់គេនេះ គឺចង្រៃណាស់ !

**ឫទ្ធី** : លោកបងដង្កូវស្អុយ... ចំណីឆ្ងាញ់មកដល់មាត់ហើយ ចេះតែទ្រាំលេបៗទៅ... សិស្សច្បងវារើសពេកដូច្នេះឯងបានវាចេះតែអត់អីលិទ្ធ...យូរៗទៅមុខស្ងួញមើលតែឆ្ងារ អត់ត្រីអាំង...បងដង្កូវស្អុយអើយ !! ដល់ស្ងួតបាយក្ដាំងទៅកុំបន្ទោសគេហ្មាំ... វាអីចឹង បានជាគេដាក់ងារបងឯងថាជាបុរសចាញ់ស្នេហ៍...

**បាសាន** : ចង់ដាក់ងារអីដាក់ទៅ ! អស់លោកធំៗច្រើនគ្នាណាស់នៅអិលអេ ធ្លាប់មានកេរ្តិ៍ឈ្មោះល្អពេកណាស់...ឥឡូវបែរជាស្អុយឈ្មោះកប់ក្នុងភក់ជ្រាំអវិចីងើបមុខមិនរួច ខូចបុណ្យសក្តិ ព្រោះតែរឿងលួចប្រពន្ធគេ... កាលណាគេលួចយើង យើងដេកលក់... កាលណាយើងលួចគេ យើងដេកមិនលក់ទេ ច្បាស់ជាកម្មតាមផ្ដន្ទាហើយ.... បងមិនចង់ដើរតាមផ្លូវអពមង្គលនេះទេ... ឧបមាថា បើទាល់ខ្លាំងណាស់... ចាត់ការជាមួយព្រះនាងហត្ថាតែម្ដងទៅក៏បានដែរ...។ អត្តាហិ អត្តនោនាថោ...ខ្លួនទីពឹងខ្លួន ។

ឬទ្ធី : សិស្សច្បង... នាងវណ្ណីនេះជាស្រីគ្មានចំណង.... គ្មានប្តីសីឯណាទេ... ចំណែកសង្សាររបស់នាងទៀតសោតជាជនបរទេស.... ទាំងពីរនាក់នេះមិនអាចត្រូវគ្នាទេ... ព្រោះវណ្ណីនាងកាន់ពុទ្ធសាសនាជាប់លាប់... តែថ្ងៃសីលឡើង នាងមិនដែលខានទៅវត្តលោកតាអិលអេ... ដែលនៅមិនឆ្ងាយពីទីនេះប៉ុន្មានទេ...ពីរនាក់នេះប្រៀបដូចជាទឹកហើយនិងប្រេងអ៊ីចឹង..។ សិស្សច្បង...ឈប់និយាយ ទុកឲ្យខ្ញុំចាត់ការ... នាងវណ្ណីនេះ គឺជាវាសនាចារគូទទុកសម្រាប់ជូនបងឯងហើយ....

អ្នកពោល : ពោលដូច្នេះហើយ... នាយឬទ្ធីក៏ស្ទុះទៅចាក់បទចម្រៀងមួយនៅលើ Stereo របស់ម្ចាស់ផ្ទះ...នូវបទ "ផើបអូនមួយខ្សឹត !!" ក្នុងគោលបំណងកំដរអារម្មណ៍របស់បាសាន នៅពេលដែលវណ្ណីនាងកំពុងជាប់នៅក្នុងបន្ទប់ទឹកនៅឡើយ...។ ដាក់ភ្លេងមួយវគ្គ...

❋❋❋



# ភាគទី៤

(បទចម្រៀង "ផើបអូនមួយខ្សឹត" បន្ថយតិចៗរហូតដល់បាត់សំឡេង ។ ស្នូរសំឡេងបើកទ្វារក្រាក...ឬទឹត...)

អ្នកពោល : នាងវណ្ណីស្លៀកសារុងចោមពុងខិតទៅខាងលើ ដែលអនុញ្ញាតឲ្យគេឃើញកំភួនជើងនាងស្រឡូតស្រឡូន... នាងមានជើងទទេ មានកន្សែងពោះគោមួយជូតលើក្បាលពីសក់ ។ នាងមានសម្បុរស្រអែមស្រស់ ។ ដោយកន្សែងពោះគោបាំងភក្រ្តនាងអស់ពាក់កណ្តាល ហាក់ដូចជាព្រះខែមួយចំណិត គឺជាសម្ផស្សលាក់មុខព័ទ្ធចំហៀង ដែលបង្ហាញទ្រង់ទ្រាយស្នេហ៍លាក់កំបាំងអនាមិកមួយ ដែលមានភាពសាហាវដូចកាំបិតកោរ ។ បាសានឃើញសំណើចរបស់នាងតែពាក់កណ្តាល ឃើញស្មានាងទទេប្រកបដោយតំណក់ទឹកភ្លឺថ្លាដូចគ្រាប់ពេជ្រ ចរណៃដែលជូតមិនទាន់អស់...ឃើញដៃនាងទន់ល្វន់ល្វតដូចប្រមោយអៃរ៉ាវ៉ាន់...។ បាសានក៏នឹកទៅដល់ពាក្យសម្តីរបស់អ្នកនិពន្ធបារាំង ឈ្មោះ Marcel Proust “On aime sur un visage, sur un souvire... sur une épaule” ។ សោភណភាពប្រផិតប្រផើយ មិនហុចឲ្យទាំងអស់នេះហើយ អាចមូលដួងចិត្តយើងឥតប្រណី ដូចគេមូល

ខ្មៅនាឡិកាបិសាច ។ មិនទាន់បានឃើញអ្វីផង បាសានទន់ខ្លួនបាក់លោងទៅហើយ...។ វណ្ណីមានសម្រស់លើសសោភានីទៅទៀត ពេលដែលនាងបើកមុខទាំងអស់ឡើងកាលណា... បាសានហាក់ដូចជាស្លុតបំពង់ក រលុងខ្លួន រលាយបេះដូង រលួយឆ្អឹងឆ្អែងទន់ខ្លួនប្រាណ ភ្លឹកភ្លាំងដូចឥណាវឃើញបុស្បា...។ អម្បាញ់មិញនេះសោះ បាសាននឹកថា គេលែងស្រឡាញ់ស្រីទៀតហើយក្នុងជាតិនេះ បន្ទាប់ពីសោភានី... ប៉ុន្តែឥឡូវនេះ ក្នុងពេលនេះបាសានដឹងថា គេរបូតរលូតទៅតាមខ្សែ ទឹកធ្ងន់ជាងមុនទៅទៀត ។ បាសានពោលរង់បំពេដួងចិត្តរបស់ខ្លួនថា :

បាសាន : ល្អអ្វីល្អម្ល៉េះទេនេះហៅល្អ ដូចទេពអប្សរពីសួគ៌ា កូនរាស្ត្រទេតើស្មើទេព្តា អាត្មាវេទនាម្តងទៀតហើយ !

ឫទ្ធី : សិស្សច្បងអាល័យគិតទៅណាទៀតហើយ ? ខ្ញុំសូម Introduce... នេះគឺបុប្ផចង្កេះភ្នំ...នែ ! នែ ! សិស្សច្បងមើលៗ បុប្ផទេវីឯណាបានប៉ុនណ្ហឹងនោះ ? វណ្ណី ! នេះគឺសិស្សច្បងរបស់ខ្ញុំ...ថាជាលោកគ្រូពូ លោកគ្រូតា ឬគ្រូឧបជ្ឈាយ៍របស់ខ្ញុំក៏ថាបាន... គាត់ចង់ប្រើឲ្យខ្ញុំធ្វើអ្វី ខ្ញុំធ្វើតាមទាំងអស់...អានី ! នេះគឺលោកបងបាសានហ្នាំ !... គឺលោកបងខ្ញុំ ! អានីឯងដែលឮឈ្មោះគាត់ទេ ? បើអានីឯងមិនស្គាល់លោកបងសាន គឺដូចជាគេមិនស្គាល់ភ្នំថៃសានអីចឹងដែរ !



វណ្ណី : ឫទ្ធី ! ពីណាគេ បុប្ផវត្តី ?

បាសាន : គឺកូនស្រីរបស់ស្តេចជំនាន់មុនហ្នាំនាង

វណ្ណី : លោកពូ... សូមទោស កូនស្តេចណា ( ឫទ្ធីហើយនឹងបាសានសើចគីលឡើងដោយហួសចិត្ត)

បាសាន : ណ្ហើយនាង... បើនាងមិនស្គាល់ក៏មិនអីដែរ..តាមពិតខ្ញុំក៏មិនសូវស្គាល់ច្បាស់ដែរ !

វណ្ណី : លោកពូកុំហៅខ្ញុំនាងអីចឹង... ខ្ញុំមិនមែនកូនក្មេងទេ... ហៅខ្ញុំវណ្ណី ឬអានីក៏បានដែរ

បាសាន : ពូហៅវណ្ណីចុះ.... ព្រោះអានីជាឈ្មោះរបស់ប្រពន្ធពូកាលពីមុន

វណ្ណី : អូ ! អីចឹងលោកពូមានប្រពន្ធហើយឬ ?

ឫទ្ធី : អានី...សិស្សច្បងខ្ញុំគាត់ធ្លាប់មានអូនកាលពីដើម ប៉ុន្តែឥឡូវគាត់ឥតមានអូនទេ ! ឥឡូវនេះគាត់កំលោះថៃស អូឡាក់យីន... ថ្មីសន្លាង បរិសុទ្ធស្អាត ច្រែសចាប់ដែបន្ទិចក៏គ្មានផង... ចំណែកសិស្សច្បងវិញ សូមកុំហៅអានី...ក្រែងច្រឡំគ្នាជាមួយនឹងអានីមុន... សូមហៅថា ហានីទៅហ្នាំ !

វណ្ណី : Hey ! don't push your luck...be cool. I'm a lady that deserves respects.... ឲ្យដឹងថាគេស្រី

អីៗផង Jerk !.... ស្អីចង់ខិតលើខិតក្រោម Honey អីទៅហើយ... ធ្វើតាមជនជាតិអាគាំងខ្លះៗទៅ ពួកគេគោរពស្រីៗណាស់... ចំណែកខ្មែរយើងចូលចិត្តតែមើលងាយស្រីៗ មិនទាន់ទាំងបានអីផង...!

បាសាន : ឫទ្ធី Please shut up ! បិទមាត់ត្រីកំភ្លាញខ្លះៗទៅមើល...វណ្ណីអើយកុំប្រកាន់ខ្ញុំ...ខ្ញុំឥតដឹងអីទេក្នុងរឿងហ្នឹង....

ឫទ្ធី : លោកបងដង្កូវស្អុយ... នៅស្ងៀមខ្លះមើល សិស្សប្អូនកំពុងតែប្រឹងធ្វើអង្គរឲ្យវាក្លាយទៅជាបាយស្រាប់ៗសម្រាប់សិស្សច្បងហូបទៅបានឆ្ងាញ់... ហើយនៅតែមិនសប្បាយចិត្តទៀត ?? កុំយកចិត្តទុកដាក់នឹងពាក្យអានី គេនិយាយលេងជាមួយខ្ញុំទេតើ... នែ៎ ! អានី... បើសិស្សច្បងខ្ញុំហៅអានីឯងថា "ហានី" នេះគឺគាត់មិនមែនមើលងាយមើលស្រាលអីទេ... ផ្ទុយទៅវិញ គាត់គោរពអានីឯងរបៀបជាអាមេរិកាំងហ្នាំ...អានីឯងមើល...ខ្មែរយើងទុកប្រពន្ធជាមាស ជាពេជ្រ ដើម្បីគេយកទៅលាក់ទុកក្នុងប្រអប់...រក្សាទុកក្នុងទូឡាំង ជាវត្ថុសក្ការៈ (ពេលនោះនាយឫទ្ធីគេថ្លែងដង្ហោយរបៀបល្ខោនបាសាក់...) "អូនមាសបង កែវចរណៃថ្លើមថ្លៃឱរ៉ា... នាងនៅទីណា សង្សារមាសបង



អើយ !!" (មកសំឡេងធម្មតាវិញ) ចំណែកអាគាំងវិញបែរជាទុកប្រពន្ធជាទឹកឃ្មុំ... ពីព្រោះវាចូលចិត្តលិតគ្រឿងផ្អែមយ៉ាងឥតអាណិត ពួកអាដែងស្អីគេហ្នឹង... បើអានីឯងចង់ឲ្យសិស្សច្បងគោរពអានីតាមរបៀបអាគាំង គឺត្រូវម៉ាច់តែម្តង... ពីព្រោះលោកបងខ្ញុំគាត់គោរព ហើយបេតីទឹកឃ្មុំដូចអាគាំងអ៊ីចឹងដែរ...មិនសូវជាចូលចិត្តមាសពេជ្រកែវកងដែលគេយកទៅញាត់ក្នុងប្រអប់នោះអ៊ីប៉ុន្មានទេ...

វណ្ណី : មិនដឹងជានិយាយឆ្កួតៗស្អីទេ ឫទ្ធី ! ...ស្អប់ណាស់ !

ឫទ្ធី : អានី...កុំមាយាដកខ្ញីច្រើនពេក... បើគេមិនមើលមកខ្លួនទេ...ខឹងថាគេមិនយកចិត្តទុកដាក់... ដល់គេសម្លឹងភ្លៀកៗដូចទឹកឃ្មុំ ថាគេមើលងាយ... សិស្សច្បងសូមជួយមើល.. ទ្រង់ទ្រាយអានីក្រពុំដូចអាយុ ១៦... ចំណែកសំឡេងវិញ ជាសំឡេងមាសដូចកុមារីអាយុ ១៣ឆ្នាំ....

វណ្ណី : កុំនិយាយលើកជើងខ្ញុំពេកមើល...ឫទ្ធី...

ឫទ្ធី : "ឫទ្ធីខ្ញុំ" មិនចេះលើកជើងទេ ...សិស្សច្បងខ្ញុំឯណោះទើបបានមានយុទ្ធសិល្បខាងលើកជើង !

វណ្ណី : មិនដឹងជាស្អីទេ... និយាយមិនឈ្នះឫទ្ធីឯងទេ... គេនិយាយអីចេះ ចេញទៅអីចុះ...

អ្នកពោល : វណ្ណីឃើញទឹកមុខបាសានស្រងូតស្រងាត់... ហាក់ដូចជាមានចិត្តអាណិតអាសូរ ហើយក៏ហាក់ដូចជាមានជាប់និស្ស័យខ្លះៗផង ។ នាងទាញកៅអីមួយមកអង្គុយជាប់ក្បែរបង្អួចនឹងបាសាន... ព្រមទាំងសម្លឹងបាសានយ៉ាងជិតបំផុត ក្រសែភ្នែកនិងទឹកភក្ត្រពោរពេញដោយស្នេហ៍

វណ្ណី : ខ្ញុំស្តាយណាស់ មិនបានដឹងជាមុនថាលោកពូអញ្ជើញមកលេង... កុំអីខ្ញុំរៀបចំម្ហូបខ្លះៗទុកជូនលោកពូពិសាមិនខាន !

បាសាន : មិនអីទេ វណ្ណី ! កុំរំខានដោយសារខ្ញុំអី...ខ្ញុំ... ឥតមានឃ្លានអីទេ.... បានវណ្ណីឯងទទួលខ្ញុំជាភ្ញៀវពិសេសដូច្នេះ សូមអរគុណព្រះអង្គទៅហើយ...

វណ្ណី : មិនអរគុណខ្ញុំ ទៅអរគុណព្រះអង្គទៅវិញ ! លោកពូចូល Church ឬ ?

បាសាន : ចុះពូហៅវណ្ណីឯងជាព្រះអង្គទៅហើយ...មិនសុខចិត្តទៀតឬ ?

វណ្ណី : (សើច...ស្ងៀមមួយសន្ទុះ)...សព្វថ្ងៃលោកពូធ្វើការអីដែរចាស... បើសិនជាមិនរំខានទេ

ប៊ូទី : បើអានីឯងសួរគាត់អីចឹង គាត់ម្តេចនឹងហ៊ាន



និយាយប្រាប់តាមត្រង់ ?.... សិស្សច្បងខ្ញុំនេះជាថៅកែរោងពុម្ពនៅអិលអេ បោះពុម្ពសៀវភៅសិក្សា សៀវភៅធម៌...ព្រះត្រៃបិដក សំបុត្រការនានា... ជាម្ចាស់ហាង Laundry បោកខោអាវនៅ Westminster...ថែមទាំងមានហាងដូណិត ៣-៤រាយប៉ាយទាំងពី ប៉ូម៉ូណា ទៅដល់ Dan Diego...ហើយខ្លួនគាត់តែម្នាក់មានឡានជិះដល់ទៅ ៥...អានីអើយ !

វណ្ណី : លោកពូប្រហែលជាសល់ប្រាក់ច្រើនណាស់មើលទៅ !

បាសាន : កុំជឿប៊ូទីនិយាយប្រឡៅសោះ... រូបពូជាមនុស្សឥតផ្ទះសម្បែង ឥតគ្រួសារ ឥតក្តីសង្ឃឹម... ល្ងីងដូចកាហ្វេអត់ស្ករ...ប៊ូទីកុំនិយាយបំផ្លើសឲ្យជ្រុលហួស បើប៊ូទីឯងភរភូតគេម្តងៗពីរឿងបង នឹងនាំឲ្យទេព្តាបរាមុខដល់ខ្លួនបងជាមិនខាន...

ប៊ូទី : សិស្សច្បងកុំដាក់ខ្លួនពេក... ចាំបាច់លាក់អ្វីខ្លាំងម្ល៉េះ បើរឿងហ្នឹងវាពិតនោះ... ប្រាប់អានីខ្លះទៅ ឥឡូវគ្នាក្លាយជាក្មួយសិស្សច្បងទៅហើយ... មានការរាក់ជ្រៅអ្វីៗឲ្យក្មួយស្រីជួយដឹងជួយឮផង ជួយដោះស្រាយទុក្ខធុរៈផង

បាសាន : ប៊ូទីឈប់និយាយលេង...និយាយអីចឹង វណ្ណី...ខ្ញុំឮថា វណ្ណីមានកូនមួយ... តើកូននោះប្រុសឬស្រី ? ហើយម្តេចក៏ខ្ញុំមិនឃើញ ?

វណ្ណី : អូ កូនរបស់ខ្ញុំស្រី... ឈ្មោះកល្យាណ... ខ្ញុំបានយកទៅផ្ញើបងស្រីខ្ញុំនៅពីរបីប្លុកពីនេះប៉ុណ្ណោះ... យីលោកពូ... ថ្ងៃស្អែកនេះជា Birthday របស់កល្យាណផង....ខ្ញុំសូមអញ្ជើញលោកពូមកជាភ្ញៀវកិត្តិយសផងបានទេ ? កល្យាណជាក្មេងគួរឲ្យស្រឡាញ់ណាស់លោកពូអើយ....

បាសាន : ពូឥតឆ្ងល់ទេ តែម្ដាយគួរឲ្យស្រឡាញ់ហើយកូនក៏គួរឲ្យស្រឡាញ់ដែរ....

វណ្ណី : បើអ៊ីចឹង សូមលោកពូមកកុំខានណា !

បាសាន : Definitely... ពូរីករាយណាស់នឹងបានមកចូលរួមក្នុង Birthday របស់កល្យាណនៅថ្ងៃស្អែក !

វណ្ណី : ខ្ញុំសូមអរគុណលោកពូណាស់ !

បាសាន : គឺខ្លួនខ្ញុំទេដែលត្រូវអរគុណវណ្ណីដែលបានហៅខ្ញុំ !

ឫទ្ធី : មិនដឹងជាអរគុណទៅ អរគុណម៉ោស្គីមិនចេះស្ងាងទេ... នែ ម៉ោង ៦ល្ងាចហើយសិស្សច្បង ខ្ញុំឃ្លានបាយណាស់....យើងគិតទៅរកដាក់អីមួយសិន !

បាសាន : ខ្ញុំដូចជាឃ្លានបន្តិចៗដែរ... វណ្ណី ! បើមិនយល់ទាស់ទេ ខ្ញុំសូមអញ្ជើញវណ្ណីទៅបាយនៅហាងសៀម... នៅ



កន្លែង Siam Center ជាមួយពួកយើង.... នៅកន្លែងនោះឆ្ងាញណាស់ វណ្ណីឃ្លានទេ ?

វណ្ណី : ចាស ឃ្លានលោកពូ... ខ្ញុំមិនបានញ៉ាំបាយថ្ងៃផងព្រោះខ្វាចធាត់....

បាសាន : អូ ! អ៊ីចឹងស្រួលហើយ... បានទេព្ដាស្រីទៅជាមួយ ពួកយើងបាយឆ្ងាញ់ស្លាប់ហើយល្ងាចនេះ !

វណ្ណី : សូមលោកពូមេត្តាចាំបន្តិច ខ្ញុំស្លៀកពាក់តែមួយភ្លែតទេ... (ដាក់ភ្លេង sentiment ដែលធ្វើឲ្យមានសង្ឃឹមប្រហែលពីរនាទី) ។

អ្នកពោល : មុននេះបន្តិចសោះ បាសានអស់សង្ឃឹមក្នុងជីវិត ព្រោះតែរបួសស្នេហាធ្លុះធ្លាយដល់ថ្លើមប្រមាត់...ប៉ុន្តែពេលនេះ បាសានមិនព្រមរាងចាល...ត្រូវរត់ ត្រូវបោល... ហក់លោតទៅជួញស្នេហ៍កសាងកម្មជាមួយស្រីថ្មី... ស្រីក្មេងលើសមុនទៅទៀត ។ កាលពីមុនជាសោភានី ឥឡូវជាវណ្ណី... ប៉ុន្តែសម្រេចសម្រួលទៅ អានីនៅតែជាអានីដដែល ។ ជួនកាលក្នុងការឈឺចាប់របស់យើង... យើងមិនអាចរកឱសថកែឲ្យបានសះស្បើយ... ដោយព្រោះខ្លួនយើងវាមិនចង់ជា... ព្រោះខ្លួនយើងវាសាច់កម្ម !!!

ពេលវណ្ណីចូលស្លៀកពាក់ក្នុងបន្ទប់របស់នាង... បាសាននឹក

ឃើញទៅដល់ពាក្យសន្យាជាមួយខ្លួនថា ខ្លួនលែងស្រឡាញ់ជាប់ចិត្តជាមួយស្រីក្មេងទៀតហើយ...បន្ទាប់ពីសោភានី ។ បាសាននឹកទៅដល់ពាក្យដែលខ្លួនឯងធ្លាប់ប្រដៅមិត្តភក្តិចាស់ទុំ... កុំឲ្យយកប្រពន្ធក្មេងពេក ព្រោះនាំឲ្យគេធ្វើបាប និងបណ្តាលឲ្យខាតអាយុ...។ បាសាននឹកទៅដល់រហូតព្រះបន្ទូលនៃព្រះសមណគោតបរមគ្រូទៀតផង : "ដូចជាបុប្ផាមួយ ដែលមានសម្ផស្សល្អ ប៉ុន្តែគ្មានក្លិនក្រអូប ពាក្យសម្តីល្អពីរោះដែលយើងមិនធ្វើតាម គឺគ្មានបានផលផ្លែផ្កាអ្វីឡើយ..."

...ក៏ដូចជាបុប្ផាដែលមានសម្ផស្សប្រិមប្រិយ ព្រមទាំងមានគន្ធពិដោរក្រអូបឈ្ងុយឈ្ងប់...ពាក្យសម្តីពីរោះល្អ ដែលយើងធ្វើតាម តែងតែហុចផលផ្លែផ្កាជានិច្ច..." ឱ ! សំណើចចំអកនៃព្រហ្មលិខិត ! (ភ្លេង)

# ឆាកទី៥

## (សូរសំឡេងទ្វារបើក និងបិទ)

អ្នកពោល : វណ្ណីនាងចូលទៅតែងខ្លួនក្នុងបន្ទប់ ។ បាសាន និងឫទ្ធី អង្គុយនៅក្នុងបន្ទប់ទទួលភ្ញៀវ...ពិភាក្សាប្តូរយោបល់គ្នាតទៅទៀត ។

ឫទ្ធី : ម៉េចទៅសិស្សច្បង ? យ៉ាងណាទៅដែរបុប្ផាវណ្ណីនារីកំពូលឃ្មុំដូចចង្កេះភ្នំ ? មុខមាត់អ្នកបងស្រីវណ្ណីគឺស្រដៀងគ្នាបេះបិទនិងអ្នកបងសោភានីរបស់បងឯងពីមុនមែនទេ ? ប្រហែលគ្នានឹងបងប្អូនភ្លោះតែម្តង ដូចគ្នាបេះបិទ ដូចទឹកពីរដំណក់... សិស្សច្បងឃើញស្រាប់ហើយ I don’t say play !

បាសាន : មែនហើយឫទ្ធី... បងសូមទទួលស្គាល់ it’s true !! ដូចគ្នានេះ គឺដូចពេកតែម្តង ! បងសឹងតែមិនជឿភ្នែកខ្លួនឯង.... ខុសគ្នាបន្តិច ត្រង់វណ្ណីស្រស់ជាងសោភានី ដោយមានសក់រួញអង្កាដីល្អជាង... ចិញ្ចើមក្រពើខ្មៅល្អជាងរាងកោងដូចដងធ្នូព្រះរាម... កំភួនជើងមិនស៊ីមិនសងគ្នាទេ... មាឌក៏ប៉ុនគ្នា ត្រគាកទៀតសោតក៏ដូចគ្នា... ប៉ុន្តែ ដើមទ្រូងវណ្ណីដូចជាមិនសូវក្បំមូលក្លំហុចទៅមុខដល់របស់សោភានីទេ !

ប៊ូទី : ខ្ញុំយល់ថា ទ្រូងមាន់ព្រៃហុចល្មមៗប្រហែលវណ្ណី... វាសមល្មមជាងណាំសិស្សច្បង !... ដើមទ្រូងសិស្សច្បងស្រីសោភានីនោះ ដូចជាទទួលភ្ញៀវរបួសពេកទេដឹង ?

បាសាន : ទោះជាយ៉ាងណាក្ដី... ប៊ូទី ! ប្អូនប្រុសបង ! ស្រីទាំងពីរនេះ គឺដូចស្រីតែមួយ... នៅតែបន្តិចទៀតបងនឹងគិតយល់ថា មានព្រាយបិសាចឯណា ឯណីវាមកលងបង... មកក្លែងខ្លួនបន្លំជាសោភានី ដើម្បីគ្រាន់តែបញ្ឆោតអារម្មណ៍របស់បងតែប៉ុណ្ណោះ !

ប៊ូទី : ឃើញទេសិស្សច្បង ? I told you វណ្ណី is your type...សិស្សច្បងគួរតែសរសើរខ្ញុំ... ឬក៏បន្តិចសញ្ញាប័ត្រសញ្ញាឃើញមួយឲ្យដល់ខ្ញុំផងទើបត្រូវ... I Know completely what you want សិស្សច្បង... (ប៊ូទីនិយាយសម្ដែងរបៀបក្នុងកុន-ល្ខោន)...Vanny ឱ ! ឱ ! ឱ ! វណ្ណីប្រមាត់របស់បង ! Vanny ... I love you baby... I love you so ! I need you honey ! I never let you go...ហេ ! ហេ ! សិស្សច្បងប្រសិនបើថ្ងៃមួយ សិស្សច្បងបានជាប់ឆ្នោតធ្វើជារដ្ឋមន្ត្រីទី១-ទី២ សូមកុំភ្លេចសិស្សប្អូនណាំ !! OK ? ខ្ញុំចង់បានកន្លែងឃោសនាការ...ឬអាក្រសួងព័ត៌មានស្អីគេនោះ !...



បាសាន : ផ្ដេសផ្ដាស ! (ស្មៀមមួយស្របក់)...ប៊ូទី...បងនៅតែតប់ប្រមល់ដដែល...

ប៊ូទី : ម៉េចអីចឹងសិស្សច្បង ?

បាសាន : Life is not designed for happiness !!... បងចេះតែនឹកឃើញទៅដល់រឿងបងយល់សប្តិបាក់ធ្មេញកាលពីយប់មិញ... បងចេះតែពិភាល់... ថារឿងវណ្ណីនេះមិនកើតទេប្អូនអើយ... យល់សប្តិបាក់ធ្មេញមានចេញឈាមផងនោះ... វាដូចជាមានសំឡេងនៃវត្ថុសក្តិសិទ្ធិដែលកំពុងតែប្រាប់បងថា រឿងវណ្ណីនិងនាំសមុទ្រទុក្ខកម្មមកឲ្យបង ដូចតែរឿងសោភានី...នោះដែរ

ប៊ូទី : ឱ ! សិស្សច្បងឆ្ងល់រឿងរហ្វឿង ដង្កូវស្អុយ...គឺសិស្សច្បងហ្នឹងឯងដែលបានប្រាប់ខ្ញុំថា..."កាលណាសង្សារវាមកដល់ក៏ទទួលយកទៅ... ហើយបើវាត្រឡប់ទៅវិញ...ក៏ឲ្យវាទៅៗ!!!" ទៅតាមដំណើរ... ទៅតាមដំណើរ ! ទឹកហូរកាត់ខ្សាច់...ដីកយកដុំអាចម៍ដូចនំចាខ្វៃ !

បាសាន : បាបកម្ម...បាបកម្ម សម្មាសម្ពុទ្ធោ...បងជឿកម្មផលណាស់ ប្អូនប្រុស...កន្លែងនេះបងមិនលេងចូលទេ...កាលណាយើងធ្វើអាក្រក់ទៅគេ... គេធ្វើអាក្រក់មកយើង... ចំណែកវណ្ណី នាងជាសង្សាររបស់គេ...

ឫទ្ធី : អាសង្សាររបស់នាង វាជាជាតិដទៃ...

បាសាន : ជាតិដទៃ ក៏វាចេះឈឺចាប់ដូចតែយើងអ៊ីចឹង... គេលួចរបស់យើងយ៉ាងម៉េច យើងចេះឈឺ...បើយើងលួចរបស់គេ ក៏គេចេះឈឺចាប់ដូចយើងដែរ... បងខ្លាចកម្មពៀរណាស់ប្អូនអើយ... គ្មាននរណាធ្វើយើង គឺយើងធ្វើខ្លួនឯង...! បងនៅចាំថា កាលបងពីក្មេងនៅខេត្តព្រៃវែង បងបានបាញ់សារិកាមួយនៅចុងអម្ពិលបារាំងឆ្ងាយសន្ធឹម ដោយកាំភ្លើង 22-long បាញ់នោះ បាញ់លេងសោះ...គ្រាន់តែសាកល្បងចង់ដឹងថាខ្លួនឯងត្រង់ ឬមិនត្រង់ប៉ុណ្ណោះ បើថាយកមកទទួលទានទៅអេះមិនជាអ្វីទេ... ប៉ុន្តែសាច់សារិកាកែវមានឆ្ងាញ់ឯណា... ឫទ្ធីអើយ... បងតម្រង់នឹកបន់ឲ្យខុសផង ស្រាប់តែធ្លាក់មកខ្ពាក ប្រកាច់ត្រុល១នៅចុងជើងបង...បណ្ដាលឲ្យវាព្រាត់គូវាតែម្ដង ។ រឿងនេះ... កន្លងទៅជាង ៣០ឆ្នាំហើយ ហើយនៅតែញ៉ូរដៃទើសសព្វថ្ងៃ ។ ចំណែកវណ្ណីនេះ...ក៏ដូចជាសារិកាដែលបងបាញ់ធ្លាក់ពីចុងឈើនោះដែរ...បងមិនចង់ឲ្យវណ្ណីព្រាត់គូរបស់គេទេ...

ឫទ្ធី : បាបចោច ! បាបចោច...បោចចាប ! ខ្ញុំបានប្រាប់សិស្សច្បងរួចហើយថា សង្សាររបស់នាងជាតិប៉ាគីស្ថាន..ជាពួកឥស្លាម...ក្រុមគ្រួសារវាមិនអនុញ្ញាតឲ្យវាយកប្រពន្ធសាសន៍ដទៃ



ទេ...វាត្រឡប់ទៅស្រុកវាវិញនេះច្បាស់ជាទៅយកប្រពន្ធសាសន៍គ្នាវាជាមិនខាន...។ សិស្សច្បង ជួយដោះទុក្ខវណ្ណីស្រីមេម៉ាយនេះ... គឺមានឈ្មោះថាសិស្សច្បងបានភ្ជួរស្រែបុណ្យទៅហើយ... មិនមែនលុកលុយក្នុងភក់អំពើបាបនោះឡើយ ។ គឺសិស្សច្បងបានបុណ្យទៅវិញតើ... ព្រះអង្គនឹងប្រទានពរសិស្សច្បងជាមិនខាន....

(ភ្លេងដំរន្ធត់មួយយ៉ាងខ្លី)...

អ្នកពោល : បាសាននៅតែមិនអស់ចិត្តសោះ។ បាសានចេះតែនឹកទៅដល់ពាក្យឃ្លានៃព្រះបរមគ្រូ...មួយវគ្គទៀត ដែលមានជំរៅជ្រៅជាងមហាសាគរទៅទៀត... ដែលឋិតនៅក្នុងព្រះធម្មបទលេខ ១២៧ : "ទោះនៅខ្ពស់ហួសមេឃទៀតក៏ដោយ... ទៅនៅកណ្ដាលសមុទ្រទៀតក៏ដោយ ទោះនៅក្នុងទីគុហាដាច់ស្រយាលនៃគិរីបព្វតាឯណាក៏ដោយ... ក៏ពុំមានទីតំបន់ណាមួយឡើយ ដែលមនុស្សអាចគេចផុត ពីអំពើអាក្រក់ទោះតែមួយក្ដី... ដែលខ្លួនបានប្រព្រឹត្ត..."

កម្មពៀររបស់យើងវានឹងបោលតាមរូបយើង... ដូចស្រមោលបោលតាមប្រាណ...។ ចំណែកវណ្ណីជាស្រែកម្ម... ពុំមែនជាស្រែបុណ្យនោះឡើយ...ដែលបាសានរៀបចំភ្ជួរជាមួយនឹងនង្គ័ល

នៃអំពើបាបរបស់ខ្លួន... ដូចដែលគេបានភ្ជួរស្រែកម្មរបស់នាងសោភានីរួចទៅហើយដូច្នោះដែរ ។ សំឡេងសម្បជញ្ញៈបានដាស់តឿននូវអំពើល្អដូចសំឡេងឧត្បោសនស័ព្ទបញ្ចូលក្នុងវិញ្ញាណរបស់បាសាន...ប៉ុន្តែគឺជាការឥតអំពើ...!!។ ពេលអង្គុយចាំវណ្ណីដែលកំពុងតែងខ្លួន បាសានទឹករហូតដល់ទៅដល់វគ្គចុងបញ្ចប់នៃការព្រាត់ប្រាសខ្លោចផ្សាឃ្លាតចាកពីសោភានី... ស្រីសង្សារចុងក្រោយពេលនាងរត់បោលចោលបាសានបាត់ទៅ... បាសានបានស្វែងរកលេខទូរស័ព្ទរបស់នាងទាល់តែឃើញ... គេបានខំអង្វរនាងតាមទូរស័ព្ទ ស្រែកអង្វរករ សុំសេចក្ដីស្នេហាចាស់ឲ្យវិលត្រឡប់វិញ !!

(សំឡេងទូរស័ព្ទ...លាយជាមួយភ្លេង)

**បាសាន** : អានី... អាណិតពូផង ឲ្យពូសុំជួបអានីឯងម្ដងទៀត

**សោភានី** : No way Jose !

**បាសាន** : អានី I miss you !

**សោភានី** : Forget it !

ហើយនាងក៏បានទម្លាក់ទូរស័ព្ទក្រឹក...។ (បញ្ឈប់ភ្លេង)

បាសានទឹកឃើញរឿងដើមទាំងអស់... ប៉ុន្តែស្នេហាថ្មីថ្មោងម្ដងទៀតក្នុងចិត្តបាសាន វាជ្រុលក្បាលក្រពើសាជាថ្មីឡើងវិញ



ទៅហើយ ។ សំឡេងនៃវត្ថុស័ក្ដិសិទ្ធបានពោលប្រាប់បាសានថា : ដំណើរវាសនាជាមួយនឹងវណ្ណី បុប្ផាចង្កេះភ្នំ... នឹងមានលំនាំទឹកភ្នែកខ្លោចផ្សាមិនសូវខុសគ្នា ឆ្ងាយពីដំណើរអភ័ព្វរហេមរហាមជាមួយនឹងសោភានីនៃ San Jose នោះឡើយ...។ បាសានរង់ចាំដោយតក់ក្រហល់... ឱវណ្ណីតែងខ្លួនរួច...អាលចេញពីបន្ទប់មកវិញ ។ ដោយពោលក្នុងចិត្ត :

**បាសាន** : I don't care ! យ៉ាងម៉េច ក៏ម៉េចទៅចុះ...ថ្ងៃណា ថ្ងៃហ្នឹងហើយ...លិចសឹមលោត ដល់គុម្ពោតសឹមតោង !

(ភ្លេង)

# ភាគទី៦

បាសានមិនបាននាំឫទ្ធីនិងនាងវណ្ណីទៅស្រស់ស្រូបអាហារភ្លាមៗដូចបានព្រាងទុកនោះទេ...។ គេបែរជាដូរចិត្តយ៉ាងរហ័សបណ្ដើរនាងទៅហាងអលង្ការមួយនៅ Hollywood ដើម្បីទិញចិញ្ចៀនពេជ្រមួយវង្សតម្លៃ ៥000 ដុល្លារ ដើម្បីធ្វើអំណោយដ៏សប្បុរសចំពោះវណ្ណី ។ ដោយបាសានពុំមានប្រាក់គ្រប់គ្រាន់ជាប់នឹងខ្លួន... គេក៏បានខ្ចី Credit card របស់ឫទ្ធីយកមកប្រើប្រាស់សិន ។ ឫទ្ធីដែលជាអ្នកជំរុញបាសានឲ្យស្រឡាញ់វណ្ណីនោះ...បែរជាបើកភ្នែកមូលៗដោយការភ្ញាក់ផ្អើលស្រឡាំងកាំង ព្រោះមិនទាន់ហ៊ានជឿថា ដំណើរការណ៍លឿនដល់ម្លឹង !! ពេលវណ្ណីនាងដើរទៅឆ្ងាយបន្តិច ដើម្បីពិនិត្យមើលអីវ៉ាន់ផ្សេងៗ... ឫទ្ធីឆ្លៀតឃាត់បាសានកុំឲ្យប្រញាប់ប្រញាល់ពេក ។

ឫទ្ធី : សិស្សច្បង... គេថាសន្សឹមៗកុំបំបោលណាំ...ចំណីចូលមាត់ទៅហើយ បងចាំបាច់អីចាយលុយច្រើនម្ល៉េះ ?... លុយប៉ុណ្ណឹងច្រើនណាស់ណាំ ទុកធ្វើ Cash flow ដើម្បីចាយឲ្យបុគ្គលិករបស់បងវិញល្អជាង...



បាសាន : ឫទ្ធី ! បងមើលតាមក្រសែភ្នែកនាងទៅ... ឃើញនាងហាក់ដូចជាមានចិត្តអាណិតបងណាស់ ហើយបងក៏អាណិតនាងវិញដែរ...អាណិតទន់ចិត្តតែម្ដង ។ ត្រង់ស្រឡាញ់... បងដូចជាគ្មានស្រឡាញ់ប៉ុន្មានទេប្អូនប្រុស...បងសួរចិត្តខ្លួនឯងរួចហើយ ប៉ុន្តែបងហាក់ដូចជាអាណិតនាងដូចប្អូនស្រី...ឬដូចកូនស្រីរបស់បងតែម្ដង...

ឫទ្ធី : អាណិតហ្នឹង វាធំជាងស្រឡាញ់ទៅទៀត...សិស្សច្បង...

បាសាន : ចុះក្រែងប្អូនឯងចង់ឲ្យបងអាណិតនាង មិនអីចឹង ? ឥឡូវម្ដេចក៏មកឃាត់ចិត្តបងទៅវិញ ?

ឫទ្ធី : អង្ករចង់ក្លាយទៅជាបាយទៅហើយ... បងចាំបាច់ថែមទឹកអ្វីច្រើនម្ល៉េះ ? បងទិញតែកាបូប Vutton តម្លៃមួយ បីបួនរយដុល្លារទៅបានហើយ...

បាសាន : មិនអីទេប្អូន... លុយប៉ុណ្ណឹងមិនមែនប៉ុន្មានទេ បងរកបាន ប៉ុន្តែចិត្ត និងនិស្ស័យដូចនាង បងរកមិនបានសោះឡើយ សូមកុំឃាត់បងអី... បងហាក់ដូចជាដឹងថា យើងទាំងពីរកើតមកសម្រាប់កសាងសេចក្ដីសុខជាមួយគ្នាប៉ុណ្ណោះ...

ឫទ្ធី : យល់ព្រម... ឲ្យតែបងសប្បាយចិត្ត ខ្ញុំលែងឃាត់

ទៀតហើយ... ហេ ! ហេ ! លោកបងខ្ញុំ...អម្បាញ់មិញថា មិនសូវចង់ទេ... ឥឡូវជាប់ង៉ង់...ក្នុងសំណាញ់ប្រចៀវហោះបណ្ដោយ !

បាសាន : កុំថាអី ថារ៉ាន់... បើថាជ្រុលជាជួយបងទៅហើយ ជួយមួយចប់តែម្ដងទៅ...កុំឲ្យដល់កំពង់លង់ទូកនោះ

ប៉ូទ្ធី : សិស្សច្បង... ប្អូនចង់តែឲ្យសិស្សច្បងសប្បាយប៉ុណ្ណោះឯង... ខ្ញុំសូមទោសដែលស្ដាយលុយជំនួសសិស្សច្បង...វាទៅជារាជានិយមលើសព្រះរាជាទៀតទៅហើយ... ឥឡូវ ដើម្បីនូវសេចក្ដីស្មោះស្ម័គ្រ ស្វាមីភក្ដិរបស់ខ្ញុំក្នុងការធ្វើសហការ... ខ្ញុំសូមធ្វើលេសថាមានជាប់រវល់... បងឯងយកខ្ញុំទៅ drop នៅផ្ទះខ្ញុំ... ហើយសូមសិស្សច្បងអញ្ជើញទៅផ្ដែមបន្ទែតែពីរនាក់ចុះមែនហ្ន៎ា !

បាសាន : យី ! ល្ងាចនេះប្អូនមិនចង់នៅកំដរបងទេឬ ?

ប៉ូទ្ធី : ភ្លេងនេះ សិស្សច្បងត្រូវលេង Solo...ម្ដេចចាំបាច់ខ្ញុំជួយវាយ cadences ?... នៅស្រុកនេះអាគារមាំៗណាស់... សូម្បីតែ Earth quake ក៏មិនងាយធ្វើឲ្យបាក់បែកផង... មិនបាច់ខ្ញុំទៅជួយសិស្សច្បងទេ... (វណ្ណីត្រឡប់មកក្បែរអ្នកទាំងពីរ) ។

វណ្ណី : ហ៊ឺ...កន្លែងនេះ របស់អ្វីក៏ល្អដែរ ! ល្អទាំងអស់ ! ឃើញអ្វីក៏គួរឲ្យស្រឡាញ់... ខ្ញុំមិនសូវចង់មកទីនេះទេ...វានាំតែបណ្ដាលចិត្តឲ្យកើតប្រាថ្នាភ្លើតភ្លើនឥតប្រយោជន៍ ។



បាសាន : វណ្ណី... បើមិនប្រកាន់ទេ ខ្ញុំសូមជូនរបស់មួយនេះជាអនុស្សាវរីយ៍ !

វណ្ណី : យី លោកពូ ធ្វើអ្វីអញ្ចឹង ខ្ញុំទទួលយកមិនបានទេ..

បាសាន : សូមវណ្ណីកុំបដិសេធ...បន្តិចបន្តួចទេ... សុំយកទៅ ខ្ញុំសប្បាយចិត្តនឹងជូនវណ្ណី... ព្រោះជានិមិត្តរូបនៃមិត្តភាពថ្មីថ្មោងរបស់យើង... បើខ្ញុំជ្រុលទិញទៅហើយៗវណ្ណីមិនយក តើខ្ញុំត្រូវឲ្យនរណាទៅវិញ ?

វណ្ណី : លោកពូចង់ឲ្យនរណាឲ្យទៅ ជារឿងរបស់លោកពូទេតើ !

បាសាន : សូមវណ្ណីទទួលយកទៅ កុំឲ្យខ្ញុំខ្មាសគេ...ឱ ! ហេតុតែ cadeau ខ្ញុំមិនថ្លៃថ្នូរ គេមិនសូវចង់បានទេ...ឥឡូវអីចេះទៅចុះ សូមវណ្ណីទទួលទុកជាទ្រព្យសម្ភប់ទៅចុះ... រួចចង់វណ្ណីបោះចោលទៅក្នុងធុងសំរាម ឬឲ្យបន្តទៅនរណាទៀតក៏មិនអីដែរ !

ប៉ូទ្ធី : សិស្សច្បង បើអានីគេមិនយកទេ... ឲ្យទៅនាងស្រីខ្មៅម្នាក់នោះទៅ... មើលហ្ន៎... វាកំពុងតែញញឹមយ៉ាងស្រស់ដាក់សិស្សច្បង សើចសល់ក៏ជាសំណើចដែរ... ពុំនោះទេ ឲ្យខ្ញុំសុំវិញមកក៏បានដែរ... កុំយកទៅបោះចោលក្នុងធុងសំរាមស្អីនោះរបស់ថ្លៃដែរហ្ន៎ា ទុកខ្ញុំយកទៅឲ្យអាមុំសង្សាររបស់ខ្ញុំវិញ ។

**វណ្ណី** : ឫទ្ធី កុំនិយាយលេង !! ខ្ញុំមានទាន់និយាយថា ខ្ញុំមិនចង់បានឯណា ?... បើកាលណាខ្ញុំមិនទាន់និយាយទេ របស់នេះជារបស់ខ្ញុំហ្នំា... មែនទេ ? (ងាកទៅរកបាសាន) លោកពូ ខ្ញុំលើកដៃសំពះដោយសេចក្ដីគោរពដូចជាឪពុកដូច្នោះហ្នំា ពីព្រោះលោកពូជាមនុស្សថ្លៃថ្នូរ កម្ររកបាន... ខ្ញុំសូមទទួលអំណោយរបស់លោកពូដោយសេចក្ដីសុទ្ធចិត្ត និងសេចក្ដីអំណរគុណរកអ្វីប្រៀបពុំបាន...

**បាសាន** : អូ៎...លើកដៃថ្វាយព្រះវណ្ណី កុំសំពះខ្ញុំធ្វើអ្វី... ខ្ញុំជាមនុស្សទេ ខ្ញុំពុំមែនជាទេព្ដាទេ...ម្យ៉ាងវិញទៀតយើងនៅសហរដ្ឋអាមេរិកទៅហើយ... មិនដឹងជាចាំបាច់សំពះធ្វើអ្វីទៀតទេ !

**វណ្ណី** : លោកពូ ! ខ្ញុំជាអ្នកកាន់លទ្ធិព្រះពុទ្ធសាសនាទៀងទាត់... ប្រកាន់ខ្ជាប់នូវទំនៀមទម្លាប់ប្រពៃណីបុរាណខ្មែរ...ខ្ញុំខំកសាងសីលទាន ប្រាថ្នាសុខុម... ខ្ញុំសប្បាយនឹងសំពះមនុស្សជាទីគោរពដូចលោកពូ... ក្មួយមិនអាចចូលចិត្តទំនៀមទម្លាប់អាមេរិចកាំងស្រែកហៃចុះ ហៃឡើង... លើកដៃដល់ក្បាលមនុស្សចាស់ទុំនោះទេ...

**បាសាន** : ចំណែកពូវិញ មានការសប្បាយចិត្តនឹងធ្វើឲ្យវណ្ណីសប្បាយចិត្ត... នែ៎ វណ្ណី... សូមទទួលយកទៅ...កុំទើស...



**វណ្ណី** : ចាំសលោកពូ...យីចិញ្ចៀនផងហ្នំ... កុំឲ្យថ្លៃពេក... បើថ្លៃពេកខ្ញុំមិនហ៊ានទទួលយកទេ...

**ឫទ្ធី** : វាគ្មានថ្លៃប៉ុន្មានទេ... គ្រាន់តែ ៥ពាន់ប៉ុណ្ណឹងតើ... បើអានីមិនសូវជាចង់បាន ឲ្យគ្នាសុំមកអាអ្ហើយ !

**ពុទ្ធោ** : ពុទ្ធោ លោកពូ ! ម្ដេចក៏ហ៊ានទិញថ្លៃម្ល៉េះ ? ម្ដេច ក៏លោកពូចិត្តល្អជាមួយក្មួយម្ល៉េះ ? តើក្មួយបានធ្វើបុណ្យអ្វីខ្លះពីជាតិមុន បានជាបានមកជាតិនេះជួបមនុស្សមានសប្បុរសធម៌ដូចលោកពូ ?

**ឫទ្ធី** : (និយាយធ្វើសំឡេងម៉្ល៉េម៉្លូ ព្រមទាំងធ្វើឫកពាដូចស្រី) ពុទ្ធោ ពុទ្ធំ...កុំឲ្យខ្ញុំធ្វើអី... ខ្ញុំឥតចង់បានទេ... តែណ្ហើយខ្ញុំទ្រាំយកតាមកម្មទៅចុះ... ធ្វើស្អីអញ្ចឹងទេ...អាក្រក់មើលណាស់... ស្អប់នេះស្អប់លោកអើយ...មាត់លើធ្វើពើហៅថាពូ មាត់ក្រោមព្រមធូរជាគូស្នេហ៍...ហេះ..ហេះ...ហេះ...

**វណ្ណី** : តាំងនិយាយឆ្កួតៗទៀតហើយ ឫទ្ធី...ប្រយ័ត្នខ្ញុំលែងឲ្យជួបមុខហ្នំា

**ឫទ្ធី** : ណ្ហើយ សិស្សច្បងស្រី...ជួបមុខតែសិស្សច្បងប្រុសទៅចុះ ខ្ញុំមិនថាអីថាវ៉ាន់ទេ...បើបានទៅឋានសួគ៌ កៀងទា អាឡៅឲ្យខ្ញុំផង...(ភ្លេង)

# ឆាកទី៧

អ្នកពោល : ជីវិតវាខ្លីពេកណាស់ ចំណែកការសប្បាយពុំបានវែងទាល់តែសោះ Les joies sant caurtes ! សេចក្ដីទុក្ខមានជាដង្ហូវដង្ហែនៅតាមមាគ៌ានៃជីវិត...ដូចហ្វូងឡាន tructs នៅតាមហ្វ្រីវ៉េ.... មានរូប មានទុក្ខ...រូបំ ទុក្ខំ អនត្តា ឧបសគ្គនៃសេចក្ដីលំបាកកាយ និងលំបាកចិត្តតែងតែមានមកដល់មួយហើយ និងមកដល់មួយទៀត ដូចទឹករលកប្រដេញគ្នា... រីឯឱកាសនៃសេចក្ដីសុខក្នុងអារម្មណ៍ រីឯវាយោនៃសុភមង្គលវិញ ជារបស់ដែលកម្រមកដល់រូបយើងពេកណាស់ ! ដូចជាផ្កាយដុះកន្ទុយ... គ្រាន់តែរសាត់មកក្រឡឹងក្បែរផែនដីមួយភ្លែតកាលណា... ក៏បែរយាត្រាត្រឡប់ទៅវិញ យ៉ាងប្រញាប់....រាប់សិបឆ្នាំ...ទើបអើតក្បាលរំសាយកន្ទុយមកវិញមួយភ្លែត ហាក់ដូចជាគ្មានស្រណោះអាឡោះអាល័យសេចក្ដីស្រណុកសុខកាយ សប្បាយនឹងការភប់ប្រសព្វជាមួយនឹងព្រះធរណីបន្តិចបន្តួចសោះ ។

...ម្ល៉ោះហើយ បើការសប្បាយបានរសាត់មកដល់ហើយ បើភ័ព្វព្រេងរត់មកទង្គិចលើរូបយើងហើយ... យើងគួរតែក្រេបជញ្ជក់ទឹកដមផ្អែមល្ហែមនៃជីវិតឲ្យបានភ្លាមៗ...ឲ្យបានពេញទំហឹង !!



កុំឲ្យវាររអិលទៅបាត់ដូចតំណក់ទឹកលើស្លឹកឈូក...ក្រេបទៅ ភ្លក្សទៅ ជញ្ជក់ទៅ នូវសេចក្ដីសុខក្សេមក្សាន្ត ទាន់ចំណីនៅផ្អែមពិសា...ហើយទាន់បំពង់កយើងនៅឈរ នៅត្រង់ ។ នេះគឺជាទស្សនៈរបស់បាសាន...បាសានជាអាយុជ្រេបន្តិចទៅហើយ ដូចថ្ងៃរសៀល ម្ល៉ោះហើយបានជាគេចង់ប្រលែងនឹងស្នេហា...ឲ្យវាបានផ្ដាំចាស់តែម្ដង...ចង់ឆក់យកខ្លឹមខ្លួន ខ្លឹមចន្ទន៍ ខ្លឹមស្នេហ៍ឲ្យបានទាន់ពេលវេលាដែលជាសម្បត្តិអមតៈ ! ស្នេហាមកដល់...ក៏ដូចជាស៊ីម៉ងត៍ទើបនឹងលាយដូច្នោះដែលនៅទន់ភ្លន់ តែកាលណាយឺតពេលតែបន្តិច...ស៊ីម៉ងត៍នេះវាក្លាយទៅជារឹងម៉ឹង មិនអនុញ្ញាតឲ្យយើងឆ្លាក់ច្នៃទ្រង់ទ្រាយសិល្បៈនៃជីវិត... ព្រមទាំងគួសវាសដងអូរនៃសុភមង្គលបានសោះឡើយ ឬពុំនោះសោតទេ សេចក្ដីស្នេហា... បើយោងតាមភាសិតអារ៉ាប់មួយ...ក៏ដូចជាស្រមោលនៃរូបយើងជាមួយនឹងពន្លឺថ្ងៃ...កាលណាយើងដេញតាមស្រមោលយើងដេញតាមវាមិនទាន់ឡើយ...ក៏ប៉ុន្តែបើស្រមោលដេញតាមរូបយើង ក៏ស្រមោលដេញតាមមិនទាន់យើងវិញដែរ : “La femme, c’est comme ton ombre au soleil, quand tu la paursuis, tu la fuis...” ក៏ប៉ុន្តែជួនកាលស្រមោលរបស់យើងវាជាន់លើរូបយើង ដូចក្បឿងត្រួតលើគ្នា...គឺនៅចំពេលថ្ងៃ

ត្រង់... ដូចនៅចំពេលនេះតែម្ដង ដែលវាសនារបស់វណ្ណីជាន់ត្រួតលើជោគជាតារបស់បាសាន ស្រមោលហើយនិងរូបកាយ ក្លាយទៅជារបស់តែមួយ !! ដូច្នេះហើយបានជាបាសាន ខំប្រញាប់ប្រញាល់ខំអង្វរករឲ្យស្រមោលនិងរូបប្រាណនៅរួមគ្នាបានយូរបន្តិច..... កុំឲ្យសេចក្ដីសប្បាយរបស់រូបគេមានអាយុខ្លីពេក...។ បាសានខំអង្វរករដូចកវីបារាំង...... សូមឲ្យវេលាផ្អាកសកម្មភាពរបស់គេបន្តិចសិន..."Le temps est dévorant ! le temps est harcelant ! O temps, suspend ton vo..."

**បាសាន** : ឱ ! ពេលវេលា... អ្នកអាចបញ្ឈប់ដំណើររបស់អ្នកបានឬទេ ? ឱ ! ស្នេហាខ្ញុំ... អ្នកអាចឋិតថេរឬទេ ? គួរតែអាត្មាអញប្រញាប់ទៅវ៉ា... ព្រោះពេលវេលាមិនរង់ចាំរូបអញឡើយ ថ្ងៃស្អែកស្នេហានឹងរសាត់បាត់ទៅហើយ ។ ថ្ងៃស្អែកឱរាខ្ញុំនឹងស្វិតស្រពោនដូចផ្ការីកផ្ការោយ... កន្លង់ក៏បាក់ស្លាប កូលាបក៏បាក់ទង..."ឱ ! ពេលវេលាកុំអាលរត់បោលចោលខ្ញុំទៅណា ! ... សុំចាំខ្ញុំផង ! សុំចាំខ្ញុំផង ! ឱវណ្ណីមាសបង ! បងសុំអូនជាជម្រក បងសុំអូនជាផែ... បងសូមស្លាប់នៅក្នុងគុហាររបស់អូនហើយ" តន់អើយ "តន់តូច នាងតូចទាំងគ្រប់ នាងធំតែយប់ ថ្ងៃតូចទៅវិញ !"



**អ្នកពោល** : ដោយខ្លាចស្រមោលស្នេហារត់ចោលបាត់... បាសានប្រញាប់ដឹកយកឫទ្ធី យកទៅទម្លាក់ចោលនៅគេហដ្ឋានរបស់គេ... ឮតែព្រូសដូចការ៉ុងជីអាចម៍គោ...រួចហើយគេប្រញាប់បើកឡាន BMW របស់ឫទ្ធី...ដឹកនាំវណ្ណីទៅបាត់ទៅទីឆ្ងាយ... ឆ្ងាយដូចកន្លែងអស្ដង្គត... ឆ្ងាយដូច twilight zone...រថយន្តគេមុជកប់ទៅក្នុងកណ្ដាលរាត្រីស្ងាត់... ក្នុងកណ្ដាលចំណោមរថយន្តរាប់ម៉ឺនសែន... ដឹកនាំព្រលឹងពីររូបឲ្យទៅលិចលង់ក្នុងសមុទ្រតណ្ហាដ៏មហាធំធេង និងមហាបោកបាចរំជើបរំជួល ។ ដំបូងបាសាននឹកស្មានថា គេគ្រាន់តែនាំវណ្ណីទៅស្រស់ស្រូបអាហារពេលល្ងាចប៉ុណ្ណោះ រួចជូននាងត្រឡប់ទៅផ្ទះនៅ Echo Park វិញ...ព្រោះវណ្ណីបានសុំថាឲ្យបាសានប្រញាប់ត្រឡប់វិលវិញ... កុំឲ្យដល់យប់ជ្រៅពេក ដើម្បីត្រូវរៀបចំបុណ្យកំណើតរបស់កូនស្រីកល្យាណឲ្យបានអធិកអធមនៅពេលថ្ងៃស្អែកឡើង...។ ប៉ុន្តែដោយគេខ្លាចពេលវេលាមិនទំនេរ..មិននៅរង់ចាំខ្លួនទេ... មិនហុចឱកាសឲ្យគេម្ដងទៀត... បាសានក៏បាននាំវណ្ណីពង្រត់ទៅដោយគ្មានទិសដៅ... ទើបធ្លាយរហូតដល់ Las Vegas ។ ជីវិតមនោសញ្ចេតនារបស់អ្នកទាំងពីរ មានភាពសែនរញ៉េរញ៉ៃញាប់ញ័រ... បាសានភ្លេចនឹកនាដល់កិច្ចការ ចំណែកវណ្ណីភ្លេចនឹកដល់កូនស្រីកល្យាណ...នឹកដល់

សង្សារជាតិប៉ាតីស្ថាន... អ្នកទាំងពីរចេញពីភោជនីយដ្ឋានមួយដើម្បីចូលភោជនីយដ្ឋានមួយទៀត... គេចេញពីសណ្ឋាគារមួយដើម្បីចូលសណ្ឋាគារមួយទៀត ។ ស្នេហាថ្មោងថ្មីមិនចេះឆ្អែតឆ្អន់ពុំមានជិនណាយ... សុភមង្គលសួនតូចធំធេងហួសប្រមាណ ពុះពោរដូចធាតុអាកាសបែកផ្កាព្រែងនៅ California ដែលទើបកន្លងទៅថ្មីៗនេះ ដែលមានភ្លៀងមួយមេធំលិចផែនដីរួចទៅហើយ.... ក៏តាំងមានភ្លៀងមួយមេទៀត បណ្ដាលឲ្យរបើកដល់ភ្នំក្រមថ្មនៃ Las Vegas ប៉ុណ្ណឹងហើយមិនអស់ចិត្ត ថែមទាំងមានខ្យល់កម្ម-វដ្ដវាត រុញធ្លាយប៉ើងរដ្ឋ Florida និង Earth quake រញ្ជួយពីសហរដ្ឋអាមេរិករហូតដល់ក្រុង Kobé នៃប្រទេសជប៉ុន ។ ពេលដែលមនោសញ្ចេតនារំជើបរំជួល ក្ដុកក្ដួលខ្លាំង វង្វេងវង្វាន់ក្រឡុកត្រឡប់ធាតុ គឺនៅពេលនោះហើយដែល... ពេលវេលាសុភមង្គលរបស់គូសង្សារទាំងពីរឋិតនៅនឹងថ្កល់ ឥតមានរង្គោះរង្គើសោះឡើយ ។ ជាត់យុថ្កាក្នុងផៃនៃសេចក្ដីសុខ ប៉ុន្តែអ្វីៗក៏មានទីចប់ ។ ពេលវេលារសាត់ទៅអស់ពីរអាទិត្យ ។ បាសានបាននាំវណ្ណីមកដល់ចង្កេះភ្នំ Echo Park វិញ...ស្រាប់តែនាងឃើញរថយន្តរបស់សង្សារប៉ាគីស្ថានរបស់នាងសំចតនៅត្រង់ចញ្ចើមថ្នល់មិនឆ្ងាយពីគេហដ្ឋានរបស់នាងប៉ុន្មាន ។ នាងឃើញ



សង្សារចាស់របស់នាងឈររេរានៅក្បែរឡានរបស់គេ... វណ្ណីក៏បង្គាប់ឲ្យបាសានបើកឡានបង្ហួសទៅបណ្ដោយ... ហួសទៅរកសេចក្ដីសុខដែលគ្មានទីចប់... ហួសទៅរកការផ្សងព្រេង ដែលស្គាល់តែការប្លែក...ប្រាសចាកនូវការអផ្សុក និងសេចក្ដីសៅហ្មងនិងការមិនស្រណុកក្នុងអារម្មណ៍ ។ ក្នុងរាត្រីនោះ បន្ទាប់ពីគេត្រឡប់ពី Las Vegas អ្នកទាំងពីរក៏បាននាំគ្នាទៅរាំលេងសប្បាយនៅរង្គសាលមួយ នៅ Montheray Park...ដែលជាទីក្រុងចិនមួយនៅ California ខាងត្បូង ។ (បរិយាកាសសប្បាយភ្លេងរាំរែក) បាសានកំពុងរាំឱបគ្នាជាមួយវណ្ណី...

**បាសាន** : វណ្ណីអូន... បងបានជួបអូនរួចហើយ បងមិនចង់ស្គាល់ស្រីណាទៀតទេ អូនជាសង្សាររបស់បងមែនពិត...មិនមែនក្លែងក្លាយនោះទេ ។ ពេលបងនៅក្នុងរង្វង់ដៃរបស់អូន ម្ដេចក៏បងសប្បាយម្ល៉េះ ? ម្ដេចក៏បងមានអារម្មណ៍ល្អម្ល៉េះ ? បងចង់តែស្រែកទៅបង្ហូកប្រាប់ទេព្ដាឲ្យបានជាសាក្សីនៃសេចក្ដីស្នេហារបស់យើង

វណ្ណី : មិនដឹងជាស្អីទេបងសាន ! ដូចជាសរសើរអូនពេកហើយ... ហើយយើងដូចជារាំរែកយូរពេកហើយមែនទេ ? បងសាន យើងគួរតែទៅលេងសួនច្បារណាមួយដ៏ល្អដែលមានភ្លើងភ្លឺចិញ្ចាចនៅ Wollywood វិញប្រសើរជាង...

**បាសាន** : វណ្ណីអូន... សួនច្បារនោះ...ទោះនៅឋានសួគ៌ាក៏មិនស្មើនឹងសួនច្បារអូនស្រី !

**វណ្ណី** : បងសានប្រាកដជាស្រឡាញ់អូនមួយជីវិតឬ ? ប្រយ័ត្នណា៎ បងគ្រាន់តែជាសត្វកន្លង់...ចំណែកអូនជាបុប្ផា...កន្លង់ក្រេបផ្ការួចហើយតែងហើរទៅបាត់... អូនសម្លឹងឃើញរូបបងជាសុភាពបុរសមែនពិត.... ប៉ុន្តែរូបបងជាព្រាននារីក៏សឹងថាបាន...តើនរណាទៅដឹង ?

**បាសាន** : បងពុំមែនជាសត្វកន្លង់ទេ... វណ្ណី ប្អូនស្រីសម្លាញ់... បងជាទឹកសន្សើមពេលថ្ងៃ តែងតែរលាយរូបកាយទៅបាត់ នៅពេលរាត្រីតែងត្រឡប់មកដល់ទីកន្លែងវិញ ដើម្បីផ្សើមបុប្ផាអូនមិនឲ្យអាក់ខាន...

**វណ្ណី** : បងឯងជាប្រុសមានប្រជ្រុលមាត់ ប្រសប់និយាយណាស់... ប៉ុន្តែអូនមិនសូវជឿទេ... អូនមិនសូវហ៊ានជឿវាសនារបស់អូនទេក្នុងជាតិនេះ...មានប្ដីទីមួយគេរត់ចោលអូន បន្សល់តែកូនកល្យាណ... មានសង្សារបាតីស្ថាន វាប្រច័ណ្ឌហួងហែងធ្វើទុក្ខបុកម្នេញមិនចេះឈប់ឈរ...បើឥឡូវអូនបាត់រូបបងសានទៀត អូនមិនដឹងរត់ទៅពួននៅទីណាទេ... បងអើយ...អូនខ្មាសគេណាស់... ប្រហែលអូនត្រូវស្លាប់ផងក៏មិនដឹង ? ឬពុំនោះទេ អូននឹងរត់ទៅបួសហើយ...



**បាសាន** : វណ្ណី... អូនកុំនិយាយផ្ដេសផ្ដាស់អញ្ចឹងអីចឹង... អូនមិនមែនត្រឹមតែស្រីមានរូបល្អប៉ុណ្ណោះទេ ប៉ុន្តែជាស្រីមានប្រាជ្ញា ដូចបុប្ផាដែលមានក្លែបល្អរួចហើយ មានក្លិនក្រអូបថែមទៀត... បងឯណាទៅចោលអូនបាននោះ ? ពេលណាអូននិយាយជាមួយបងៗ មានអារម្មណ៍សែនសប្បាយរីករាយ...បងភ័យខ្លាចតែអូនទេវិញទេ ដែលចាកចោលបង !

**វណ្ណី** : អូនមិនចាកចោលបងទេ... អូនពុំមានទ្រនំឯណាទៀតទេ បងសម្លាញ់ !

**បាសាន** : បើដូច្នោះ សូមឲ្យស្នេហាយើងបានជាអមតៈហ្ន៎ !

**វណ្ណី** : ចាំស ! សូមឲ្យស្នេហាយើងក្លាយជាអមតៈ ! ប៉ុន្តែអូនចេះតែមានប្រផ្នូលថា

យើងមិនបានជួបគ្នារហូត...(ចាក់ចម្រៀងនាងហួយ មាសដែលចង់ទៅសាងផ្នួស)។

អ្នកពោល : ស្នូរសំឡេង Pager...បាសានចុច Beeper របស់ខ្លួន ឃើញលេខទូរស័ព្ទរបស់ឬទ្ធី ។ ឬទ្ធីមិនដែលហៅបាសានក្នុងកណ្ដាលរាត្រីដូច្នេះទេ...វៀរលែងតែមានកិច្ចសំខាន់ណាស់ ឬ emergency call...។ បាសានហាក់ដូចជាមានការបារម្ភក្ដុកក្ដួលក្នុងចិត្ត...ទុកវណ្ណីឲ្យក្រេបភេសជ្ជៈតែម្នាក់ឯង...

ចំណែកខ្លួនគេក៏

ដើរតម្រង់ទៅរកកន្លែងមួយដែលមានទូរស័ព្ទសាធារណៈ (សំឡេងទូរស័ព្ទរោទ៍ក្រឹង)

ឫទ្ធី : អាឡូ ! អាឡូ !

បាសាន : Hello ឫទ្ធី You page me ? what's going on ? what's up man ?

ឫទ្ធី : បង ! បង ! (ឫទ្ធីនិយាយមិនចង់ចេញ)... បងសាន...សុំបងកុំព្រួយចិត្តពេកណាបងណា !

បាសាន : ឫទ្ធី...មានរឿងអីប្អូន? សូមប្រាប់បងមក !

ឫទ្ធី : មានរឿងធំ...រឿងធំណាស់បង

បាសាន : រឿងអ្វីធំនោះ... ម្តេចក៏ប្អូនមិនប្រាប់មក ?

ឫទ្ធី : ខ្ញុំបានដំណឹងពីលោកពូ ប៊ុន ឫទ្ធ ដែលត្រូវជាឪពុកមារបស់បងនៅ San Jose នោះណា...បង...បង...ខ្ញុំមិនហ៊ាននិយាយទេ ខ្លាចបងពិបាកចិត្ត

បាសាន : (គំហក)... ឫទ្ធីឯងឆ្កួតទេឬ ? បើប្អូនមិននិយាយ ហ្នឹងហើយដែលធ្វើឲ្យបងកាន់តែពិបាកចិត្តឡើង

ឫទ្ធី : គឺរឿងកូនប្រុសរបស់បងណា... អា ចន្ទនី...វាមានគ្រោះថ្នាក់ឡាន...



បាសាន : ហ្អាក...រួចយ៉ាងម៉េចទៅហើយប្អូន ? របួសធ្ងន់ឬស្រាល ?

ឫទ្ធី : វាស្លាប់បីថ្ងៃរួចមកហើយ !

(បាសាននិយាយលែងចេញ...សំឡេងខ្លួងខែក)

ឫទ្ធី : ស្អែកព្រឹកនេះ គេធ្វើបុណ្យបញ្ចុះសពវានៅវិហារ Church មួយឯ San Jose... បងអាចអញ្ជើញទៅទាន់ឬទេ ? បងសាន...បងស្តាប់ប្អូនសិន... កុំគិតច្រើនណា (សំឡេងខ្លួងខែក)។

# ឆាកទី៨

(ភ្លេង tract 18)

អ្នកពោល :

តែក្នុងពីរបីវិនាទីប៉ុណ្ណោះសោះ ជីវិតរបស់លោក សរ បាសាន ត្រូវទទួលបរាជ័យ ដូចដីទន្លេបាក់ច្រាំង ធ្លាក់ទាំងផ្ទាំងទៅក្នុងទឹក...ឬក៏សឹងថា ត្រូវព្រះធរណីស្រូបទាំងរស់តែម្តងផង ។ ឱរាគ្រាំគ្រា ខ្ទេចខ្ទាំរបើករបាញ... រនាំងការពារផ្ទៃក្នុងទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ត្រូវស្រុតរលំខ្ចាត់ខ្ចាយ រលាយអស់រលីងទាំងសេចក្តីសប្បាយ... សេចក្តីក្លាហានក្នុងជីវិត រលត់ទាំងសេចក្តីសង្ឃឹមសូន្យសោះផង ។ ទាំងវិញ្ញាណធំ វិញ្ញាណតូច សូម្បីស្មារតីបន្តិចបន្តួច បានបោលចេញត្រសង គ្មានសល់ពីរូបគេ... ។ បាសាន នៅសល់តែរូបកាយប៉ុណ្ណោះ... គ្រាន់តែជាថ្មចម្លាក់ ដែលមិនអាចប្រឈមមុខនឹងសេចក្តីទទួលខុសត្រូវរបស់ខ្លួន ។ គេនៅឈរឆ្អឹង លែងឆ្លើយតបទៅបុទ្ធិតាមទូរស័ព្ទ... លែងគិតឃើញអ្វីទាំងអស់ លែងទាំងដាក់ប្រដាប់ទូរស័ព្ទ ទៅកន្លែងស្រួលបួលដូចដើមឲ្យគេវិញផង ។ បុទ្ធិនិយាយតែម្នាក់ឯងក្នុងសេចក្តីតក់ស្លុតពន់ប្រមាណ



ចំណែកបាសានវិញ ស្រមៃឃើញឡានបុកគ្នា (Sound tract)... ឃើញមុខមាត់ចន្ទនីខូចខ្ទេចខ្ទីអស់ហើយ...

បុទ្ធិ : បងសាន... បងធ្វើអ្វីហ្នឹង ? ម្តេចបងមិនឆ្លើយមកខ្ញុំអីចឹង ? បងស្តាប់ខ្ញុំឮទេ ?...បងសាន...បងសាន...បងសាន !!

អ្នកពោល : ដូច្នេះក្នុងបីថ្ងៃមិននេះសោះ នៅពេលដែលបាសានត្រូវគួចពេញទំហឹង ឈ្លក់វង្វេង អណ្តែតទៅតាមខ្សែទឹកនៃកាមគុណ... កូនប្រុសច្បងរបស់គេបានត្រូវទទួលមរណភាពដោយអាណោចអធ័មជាទីបំផុត...ពោលគឺដោយគ្មានឪពុកម្តាយនៅក្បែរខ្លួនគេសោះ...ក្រៅតែពីមារបស់បាសានម្នាក់ឈ្មោះ សរ ប៊ុនបុទ្ធ និងអ្នកមីង យីហ៊ុបដែលត្រូវជាភរិយាគាត់ ។ តាមពិតបាសាន ដែលជាមនុស្សមានជោគជ័យជាមួយស្រីៗ...ធ្លាប់តែបានដើរពង្រាយកូនច្រើនណាស់ ស្ទើរគ្រប់កន្លែង...តាំងពីស្រុកខ្មែរ...រហូតមកដល់ស្រុកបារាំង រហូតមកដល់សហរដ្ឋអាមេរិកថែមទៀត...បើរាប់ទៅសឹងតែ ១៥នាក់ទៅហើយ ទាំងប្រុសទាំងស្រី ដោយម្តាយផ្សេងៗគ្នា ។ ប៉ុន្តែ ចន្ទនីនេះ ជាកូនច្បង ជាលទ្ធផលនៃសេចក្តីស្នេហាទី១ ដែលបាសានធ្លាប់ស្រឡាញ់ជាងគេបំផុត...ព្រោះកូននេះមានប្រាជ្ញាខ្ពស់...វាងវៃ មានឫកពាថ្លៃថ្នូរ ហើយមុខមាត់ដូចខ្លួនបេះបិត ។ ចន្ទនីមានអាយុ ២៤ឆ្នាំ...កំពង់

រៀនវិស្វករបច្ចេកសាស្ត្រផ្នែកកាំជ្រួចអវកាសនៅសកលវិទ្យាល័យអាមេរិកាំងដ៏ល្បីបំផុតនៅ San Jose...នៅសល់តែ ៦ខែទៀតសោះ នឹងត្រូវប្រឡងចេញយកសញ្ញាប័ត្រចង់ចប់ទៅហើយ... ម្យ៉ាងទៀតបាសានរៀបចំនឹងទិញរថយន្ត sport មួយម៉ាក Ford Mustang ជំនាន់ថ្មី ដែលមានរូបសេះរត់នៅខាងមុខ Capot... តម្លៃជាង ២ម៉ឺនដុល្លារឲ្យជារង្វាន់ក្នុងការខំប្រឹងប្រែងរៀនសូត្រ ព្រោះគេដឹងថា កូនគេស្រឡាញ់រូបសេះដែលវាផាយ !!...ទើបតែមានគោលបំណងប្រុងប្រៀបបានប៉ុណ្ណោះ ក៏ស្រាប់តែកូនស្លាប់បាត់ទៅហើយ ។ ឪពុកស្លាប់មុនកូន គឺជារឿងធម្មតា...ប៉ុន្តែកូនស្លាប់មុនឪពុក គឺជាវាសនាអភ័ព្វ បញ្ច្រាសពីធម្មជាតិខ្លាំងពេកណាស់... វាទុក្ខសោកសង្រេងទ្រាំពុំបានចំពោះរូបឪពុកដែលនៅរស់... គឺគ្រាន់តែដើម្បីឲ្យបាសានក្រឡេកមើលទិដ្ឋភាពនៃកូនប្រុសខ្លួនអាយុជាង ២០ឆ្នាំ...ដែលចាកឋានទៅដោយមិនទាន់ទាំងបានស្គាល់រសជាតិនៃជីវិតផង ។

កូននេះកើតក្នុងឆ្នាំ ១៩៧១ ក្នុងសម័យសាធារណរដ្ឋរបស់លោក លន់ នល់...បាសាននឹកដល់អនុស្សាវរីយ៍ចាស់ៗ អនុស្សាវរីយ៍នៃការភិតភ័យរបស់ខ្លួន ដោយថ្ងៃមួយនៅក្នុងឆ្នាំ ១៩៧៣ ដែលកូននោះមានអាយុមិនទាន់បានពីរឆ្នាំ ស្រួលបួលផង...ស្រាប់តែ



បាសានបាត់រូបវាពេញមួយថ្ងៃ តាំងពីព្រឹកទល់ល្ងាច ។ កាលនោះបាសានជានាយទាហានបើកឡាន Jeep រកកូនគ្រប់ទីកន្លែងនៅម្តុំលូទឹកស្អុយ ។ នៅពេលដែលបាសានទាល់ចំណេះទៅហើយ គេបានទៅរកចន្ទនី ឃើញនៅផ្ទះចិនលក់គុយទាវម្នាក់ចម្ងាយប្រមាណ ២គ.ម ពីផ្ទះ ។

ចូលមកដល់ឆ្នាំ១៩៧៥... បាសានបានទៅនៅស្រុកបារាំងជាមួយគ្រួសារ គឺភរិយាដើមហើយនិងចន្ទនី ។ ជីវិតសម័យនោះលំបាកពន់ពេក... បាសានធ្វើការក្នុងរោងចក្របារាំងវេលាយប់... ហើយបាសានចេះតែមួម៉ៅ ក្តៅក្រហាយច្រើនក្នុងចិត្ត ព្រមទាំងទាស់ទែងជាមួយភរិយា... ហើយវាយទះតប់កូនខ្លួនឯង គឺចន្ទនី ដែលវាទើបមានអាយុ ៤ឆ្នាំសោះ ដោយអយុត្តិធម៌..ដោយគ្មានរឿងហេតុធំដុំ... ព្រោះតែវាបានលោតទន្រ្ទាំបន្តិចបន្តួចតាមចរិតក្មេង បណ្តាលឲ្យបាសាននិទ្រាមិនបាន ។ ទិដ្ឋភាពមួយដែលបាសានមិនអាចបំភ្លេចបានរហូតមកទល់ពេលនេះ គឺថ្ងៃមួយគេបានខោកក្បាលកូននៅក្នុងបន្ទប់ទឹក ព្រោះតែវាមិនព្រមឈប់យំពេលដែលម្តាយវាងូតទឹកឲ្យ...។ បាសានវាយតប់ចន្ទនីរហូតដល់ហូរឈាមច្រមុះអស់កន្លះផ្តិល... ហើយក៏តាំងអាណិតអាសូរកូនស្តាយកំហុសនេះរហូត ២០ឆ្នាំក្រោយមក ។

ថ្ងៃមួយទៀតនៅស្រុកបារាំង...ឆ្នាំ១៩៧៦ នៅរដូវត្រជាក់ ភរិយាបាសានបានកើតជំងឺរបេង...បាសានបានយកចន្ទនីទៅផ្ញើនៅអង្គការមនុស្សធម៌កាតូលិកបារាំងមួយ ដែលជួយចេញសោហ៊ុយយ៉ាងថ្លៃ ១ខែពីរពាន់ហ្វ្រង់ ដើម្បីបញ្ជូនចន្ទនីឲ្យទៅរស់នៅតាមខេត្តចំនួន ៣ខែ........ នៅក្នុងគ្រួសារបារាំងមួយនៅស្រុក Romorantin ចម្ងាយប្រហែល ២00គ.ម ពីទីក្រុង Paris ។ បាសានអាចទៅលេងកូនក្នុងមួយខែម្តង... ឬក៏ចង់យកកូនមកវិញនៅពេលណាក៏បាន ។ នៅក្នុងខែទី១ ពេលបាសានទៅលេងកូន ចន្ទនីវាស្រែកឡាំប៉ាទារយំតាមឪពុកឃាត់មិនឈ្នះ..។ គេបង្ហាញរូបថតវាដែលលេងជាមួយកូនបារាំង... បាសានបានសង្កេតឃើញទឹកមុខកូនសែនព្រួយ មុខមិនរីក ស្មើផេងដូចថ្ងៃបាំងពពក ។ ប៉ុន្តែបាសានមិនបានសម្រេចយកកូនមកវិញសោះ ។ នៅខែទី២ បាសានបានទៅលេងកូនសាជាថ្មី... ឃើញវាស្រែកយំទារតាមមកម្តងទៀត... បាសានអាណិតវាចង់ស្រក់ទឹកភ្នែក ប៉ុន្តែសម្រេចទុកវាឲ្យនៅគ្រប់ខែ...បំណាច់នឹងអង្គការសប្បុរសចេញសោហ៊ុយថវិកាថែទាំវាសន្ធឹកសន្ធាប់ ។ ប៉ុន្តែនៅខែទី ៣ ដែលបាសានត្រូវទៅយកវាត្រឡប់មកផ្ទះវិញ... ស្រាប់តែចន្ទនីវាឈរមើលបាសានពីចម្ងាយ ដោយផ្ទៀងក បញ្ឡៀងភ្នែក...ដូចជាអ្នកដទៃ ដូចជា



មនុស្សមិនស្គាល់គ្នា ឬក៏ដូចតួម្នាក់នៅក្នុងរឿងភាពយន្តអាមេរិកាំង One flew over the coo koo Nest...ដែលគេកាត់សរសៃក្បាលទៅលែងស្គាល់នរណា... ចង់ប៉ាវាមកយកវិញក៏បាន មិនមកយកវិញក៏បាន ។ ជាយូរថ្ងៃណាស់ យូរសប្តាហ៍...ទើបបានចន្ទនីវាស្គាល់ រួសរាយជាមួយឪពុកម្តាយវាវិញ... ទើបបានវានិយាយចេញ ។ នៅពេលវាធំឡើង អាយុ ១៥ឆ្នាំ... នៅសហរដ្ឋអាមេរិក... បាសានត្រូវទទួលសេចក្តីតក់ស្លុតមួយសាទៀត ដោយចន្ទនីវាប្រាប់ថា... កាលពីក្មេងដែលវាទៅរស់នៅក្នុងគ្រួសារបារាំងនោះ... គេបានវាយវាជ្រមុជក្បាលឲ្យស៊ីលាមកខ្លួនឯងដោយវាយំពេក ហើយនឹងកើតរោគរាកផង...!!

ក្នុងពេលនេះ ដែលចន្ទនីបានស្លាប់ទៅហើយ...បាសានខានជួបមុខកូនអស់រយៈពេលចំនួន ៥ឆ្នាំ...ដោយរវល់តែនឹងរឿង Business ពេក និងរវល់នឹងរឿងស្នេហាផ្ទាល់ខ្លួនច្រើនពេក ។ ក៏ដូចតែពីក្នុងអតីតកាលផងដែរ ។ ចន្ទនីមុនដំបូងវាចេះសួររកឪពុកវាដូច្នេះដែរ..."តើប៉ាខ្ញុំធ្វើអ្វីទៅហើយ ? តើគាត់សុខសប្បាយឬទេ ? ចុះម្តេចក៏ខ្ញុំមិនដែលឃើញគាត់សោះ ?" ប៉ុន្តែបន្ទាប់មកចន្ទនីវាលែងចង់សួរ លែងចង់ដឹងឮ លែងចង់ស្គាល់ឪពុកវា... ឬក៏លែងទាំងស្តាប់ទៀតទៅហើយផង... ដូចដែលកាលវានៅរស់

នៅក្នុងគ្រួសារបារាំងកាលពីក្មេងដូច្នេះ ។ កាលដែលវាស្លាប់ទៅនេះ...ចន្ទនីហើយនិងបាសាន ហាក់ដូចជាជនបរទេសពីរនាក់ទៅវិញទៅមក ដូចជាមនុស្សមិនស្គាល់គ្នា !!! ។

នឹកឃើញមកដល់ត្រឹមនេះ... បាសានទម្លាក់ទូរស័ព្ទឲ្យវាធ្លាក់យូរតែកតោក ដូចប៉ោលនាឡិកា... ហើយអង្គុយទ្រូញយំង៉ោងតែម្តង...ឮខ្លាំងដូចគេយំនៅពេលដែលគេហែខ្មោចយួន ។

បាសាន : ( យំហ៊ូ !) (track 14-after 1min 35)

អ្នកពោល : មួយខែក្រោយមក វណ្ណីវាយលេខទូរស័ព្ទទៅរកបាសានម្តងទៀត...

វណ្ណី : បងសាន... ម្តេចក៏បងលែងមកលេងអូនសោះ ?

បាសាន : វណ្ណី... អូនដឹងរួចអស់ហើយមែនទេ ? មិនចាំបាច់បងពន្យល់ទេ មែនទេ ?

វណ្ណី : បងសាន...បងច្បាស់ជាទុកអូនជាស្រីចង្រៃម្នាក់ហើយ ដែលបណ្តាលឲ្យកូនបងស្លាប់នោះឬ ?

បាសាន : វណ្ណី...ស្តាប់បងសិន... មិនមែនអញ្ចឹងទេអូន... ប្រសិនត្រឹមមានទន្លេ ឬស្ទឹង ខ័ណ្ឌផ្លូវបង... បងនឹងហែលឆ្លងទៅជួបអូន... ប៉ុន្តែសពរបស់ចន្ទនីកូនរបស់បងនេះ...គឺជាសមុទ្រណាអូន... គឺមហាសមុទ្រ ដែលខ័ណ្ឌផ្លូវបង...ខ័ណ្ឌនេះ គឺខ័ណ្ឌដាច់អាល័យ...



វណ្ណី : បងសាន...សូមបងប្រមូលស្មារតីឡើងវិញ ! រឿងគ្រោះថ្នាក់កូន... វាមិនមែនមានតែចំពោះបងម្នាក់ទេហ្នា... គឺមានសឹងគ្រប់គ្នា...ក្មេងៗឥឡូវវាបើកឡានឥតដឹងអីទេ... ម្យ៉ាងទៀត ពេលគ្រោះថ្នាក់នោះ កូនរបស់បងវាខុសផង ព្រោះវាបត់ឆ្វេង...ហើយបណ្តាលឲ្យស្លាប់គ្រួសាររបស់ខាងគេដល់ទៅបីនាក់ បងឃើញទេ... គេមានទុក្ខច្រើនជាងបងទៅទៀតណា ! ហើយខាងគេនោះឥតមានខុសអ្វីសោះ !

បាសាន : វណ្ណីអូន... បើអូននៅមានសន្តានចិត្ត អាណិតអាសូរ និងស្រឡាញ់បង... ហើយបើអូនចង់ឲ្យបងនៅគោរពនិងអាណិតអូន... សូមអូនឈប់ប្រើពាក្យអសប្បុរសទៅលើកូនបងទៀត... ចន្ទនីវាស្លាប់ទៅហើយ...វាបានបង់ថ្លៃកំហុសរបស់វារួចទៅហើយ ។

វណ្ណី : បងសាន... អូនចង់ជួបបង... បើអត់រូបបងទេ តើអូនត្រូវរំពឹងលើនរណា ?

បាសាន : វណ្ណីអូន... ចុះក្រែងបងបានស៊ីញ៉េហាងដូណិតឲ្យអូនដល់ទៅបី... ព្រមទាំងហាងបោកខោអាវឲ្យអូនមួយទៀត ប៉ុណ្ណឹងហើយ អូនអាចចិញ្ចឹមខ្លួនអូន និងកូនបានមួយជីវិត...!!

វណ្ណី : ប៉ុន្តែអូនត្រូវការរូបបង

បាសាន : មិនអាចទៅរួចទេអូនស្រី... បងរៀបចំទៅសាងភ្នួសនៅស្រុកខ្មែរហើយ..."ចាំជាតិក្រោយចុះ បើខុសទៅហើយក្តីប្រាថ្នា"... យើងគួរលាងសម្អាតកម្មពៀរដែលវាបំបែកយើងនៅជាតិនេះ ទើបយើងប្រហែលនឹងអាចជួបគ្នានៅជាតិមុខ ។

វណ្ណី : (យំខ្សឹកខ្សួល)

អ្នកពោល : ដោយពោលពាក្យចុងក្រោយនេះ បាសាននឹកទៅដល់ពាក្យអ្នកនិពន្ធបារាំង Jean Jacques Rousseau ក្នុងប្រលោមលោក "La vertu qui nous sépara sur cette terre nous unira dans le séjour eterrnel"

ដាក់ភ្លេង ២ នាទី track 15 (Good after 1minute) បន្ទាប់មកដាក់ភ្លេង"ចាំជាតិក្រោយចុះរបស់លោកស៊ិនស៊ីសាមុត"

ល្ខោននិយាយរឿង បាក់ធ្មេញ បានត្រូវនិពន្ធចប់នៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៥ នៅ Long Beach ។ អ្នកនិពន្ធ សុទ្ធ ប៉ូលីន បានបញ្ជាក់ថា ... លោកបានសរសេររឿងនេះ ជាចំណងដៃឲ្យមិត្តម្នាក់ឈ្មោះ ឈុន ឫទ្ធី ឬ Alexander Chhun ឈ្មោះក្រៅហៅថា ហូ ទាហូ !!!

**ចប់ដោយបរិបូណ៌**